# វគ្គកសាងសមត្ថភាព
# សំរាប់ក្រុមប្រឹក្សាឃុំ
# ស្តីពី
# បញ្ហាការអប់រំ
# ដែលប៉ះពាល់ដល់នារី និងកុមារ

library.ncdd.gov.kh
007913

បណ្ណាល័យ
គ.ជ.ស.ប

# គំរោងមេរៀន

# វគ្គកសាងសមត្ថភាព សំរាប់ក្រុមប្រឹក្សាឃុំ
## ស្តីពី
# បញ្ហាការអប់រំដែលប៉ះពាល់ទៅលើនារី និងកុមារ

354-968
OHI.COM
sh: Training

# កម្មវិធី

## វគ្គបណ្តុះបណ្តាលគ្រូបង្គោល សំរាប់
## វគ្គកសាងសមត្ថភាព សំរាប់ក្រុមប្រឹក្សាឃុំ
## ស្តីពី បញ្ហាការអប់រំ ដែលប៉ះពាល់ទៅលើនារី និងកុមារ

| ថ្ងៃ | រយៈពេល | កម្មវិធី | អ្នកសំរបសំរួល |
|---|---|---|---|
| ថ្ងៃទី១ | | **ផ្នែកទី១ : ការចាប់ផ្តើម** | |
| | ៤៥ នាទី | គោលបំណង និង វិន័យវគ្គសិក្សា | |
| | ៦០ នាទី | រចនាសម្ព័ន្ធវគ្គកសាងសមត្ថភាព | |
| | ១៥ នាទី | ពិនិត្យឯកសារឡើងវិញ | |
| | ៦០ នាទី | **ផ្នែកទី២ : ការអប់រំគឺជាយុទ្ធសាស្រ្តកាត់បន្ថយភាពក្រីក្រ** | |
| | ១៥ នាទី | សង្ខេបពត៌មាន | |
| | ១២០ នាទី | **ផ្នែកទី៣ : ការថែទាំ និងការអភិវឌ្ឍន៍កុមារភាពក្នុងវ័យដំបូង** | |
| | ១៥ នាទី | ពិនិត្យឯកសារឡើងវិញ | |
| | ១២០ នាទី | **ផ្នែកទី៤ : ការអប់រំជាមូលដ្ឋានក្នុងប្រព័ន្ធ** | |
| | ១៥ នាទី | ពិនិត្យឯកសារឡើងវិញ | |
| | ៩០ នាទី | **ផ្នែកទី៥ : ថ្នាក់ៗអក្ខរកម្ម** | |
| | ១៥ នាទី | ពិនិត្យឯកសារឡើងវិញ | |
| | ៩០ នាទី | **ផ្នែកទី៦ : សមធម៌ផ្នែកយែនឌ័រ- ការអប់រំសំរាប់កុមារី** | |
| | ១៥ នាទី | ពិនិត្យឯកសារឡើងវិញ | |
| | ៩០ នាទី | **ផ្នែកទី៧ : ផែនការសកម្មភាព** | |
| | ១៥ នាទី | ពិនិត្យឯកសារឡើងវិញ | |
| | ៤៥ នាទី | **ផ្នែកទី៨ : ការវាយតំលៃ** | |

**កំណត់សំគាល់:**

ការកំណត់ពេលវេលា : ពេលវេលា ដែលបានកំណត់នៅក្នុងមេរៀននិមួយៗគឺគ្រាន់ជាការគ្រោងទុកការកំណត់ពេលវេលាអាចផ្លាស់ប្តូរផ្អែកទៅតាមការបណ្តុះបណ្តាលគ្រូបង្គោល។

ការពិនិត្យឯកសារឡើងវិញរបស់គ្រូបង្គោល : វាត្រូវបានរំពឹងថាសិក្ខាកាមជាគ្រូបង្គោលនឹងចំណាយពេលវេលានៅក្នុងសកម្មភាពនិមួយៗតិចជាងសិក្ខាកាមនៅថ្នាក់សហគមន៍។ ដើម្បីអោយគ្រូបង្គោលបាននិយាយពីមេរៀន សំភារៈដែលត្រូវប្រើប្រាស់ និងវិធីសាស្រ្តគួរកំណត់រយៈពេល២០នាទីបន្ទាប់ពីបញ្ចប់មេរៀននិមួយៗសំរាប់ពិនិត្យឯកសារឡើងវិញ ដែលអាចអោយគេពិភាក្សាអំពីវិធីសាស្រ្ត និងមតិយោបល់ត្រឡប់ពីវិធី ដែលអាចកែសំរួលគំរោងមេរៀនអោយកាន់តែមានប្រសិទ្ធភាពនៅថ្នាក់បន្ទាប់។

## ផ្នែកទី១ : ការចាប់ផ្តើម

**តើអ្វីជាហេតុផលសំរាប់វគ្គសិក្សានេះ?**

- លើកកំពស់ការយល់ដឹងបញ្ហាពាក់ព័ន្ធដល់សុខភាព ការអប់រំ និងកិច្ចការពារកុមារ និងការវិភាគរកមូលហេតុដែលមានស្រាប់
- កំណត់សេវាសមស្រប ដើម្បីបំពេញចន្លោះ ខ្វះខាតទាំងនេះ
- តើអ្វីដែលក្រុមប្រឹក្សាឃុំអាចអនុវត្តដើម្បីដោះស្រាយបញ្ហាទាំងនេះ

**តើអ្នកណាជាអ្នកសំរបសំរួល និងអ្នកមានធនធាន?**

ឯកសារសំរាប់វគ្គកសាងសមត្ថភាពនេះរៀបចំឡើងដើម្បីអោយអ្នកសំរបសំរួលដែលមានជំនាញ និងមានចំណេះដឹងលើបញ្ហាដែលទាក់ទងដល់នារី និងកុមារ និងវិមជ្ឈការនៅក្នុងប្រទេសកម្ពុជា ប្រើប្រាស់។ នៅក្នុងខេត្តគោលដៅ**សិទ្ធិកុមារ**អ្នកសំរបសំរួលត្រូវចេញពីក្រុមកសាងសមត្ថភាព គ.ក.ន.ក ថ្នាក់ខេត្ត និងស្រុក។ ចំពោះអ្នកមានធនធានគឺត្រូវជាសមាជិកដែលតំណាងអោយក្រសួងជំនាញពាក់ព័ន្ធ។

**តើអ្នកណាជាសិក្ខាកាមនៅក្នុងវគ្គនេះ?**

សិក្ខាកាមសំរាប់វគ្គនេះគឺ ក្រុមប្រឹក្សាឃុំ គ.ក.ន.ក មេភូមិ និងជំនួយការភូមិ ក្រុមគាំទ្រសុខភាពភូមិ ភ្នាក់ងារសុខភាពភូមិ(ចំពោះបញ្ហាសុខភាព) អ្នកធ្វើការងារសង្គមរបស់ឃុំ និងអ្នកតំណាងភូមិពាក់ព័ន្ធដទៃទៀត។

**តើត្រូវប្រើប្រាស់សំភារៈយ៉ាងដូចម្តេច?**

សំភារៈទាំងនេះបានចងក្រងឡើងជាគំរោងមេរៀនសំរាប់វគ្គសិក្សានៅថ្នាក់សហគមន៍ ដែលរយៈពេល២ថ្ងៃ។ គ្រូបង្គោលអាចជ្រើសរើសដាក់បញ្ចូលគ្រប់ប្រធានបទទាំងអស់ទៅក្នុងការបណ្តុះបណ្តាលថ្នាក់ឃុំ ឬផ្តោតតែទៅលើប្រធានបទខ្លះៗ។ ដោយសារក្រុមកសាងសមត្ថភាព គ.ក.ន.ក ថ្នាក់ខេត្ត និងស្រុកយល់ដឹងពីស្ថានភាពក្នុងខេត្តស្រុកបានប្រសើរជាងអ្នកដទៃ ពួកគេស្ថិតក្នុងតំណែងដ៏ប្រសើរ ដើម្បីធ្វើសេចក្តីសំរេចលើសំណើរទាំងនោះ។

ឯកសារដដែលនេះនិងត្រូវយកទៅប្រើប្រាស់សំរាប់បណ្តុះបណ្តាលគ្រូបង្គោល ដែលមកពីក្រុមកសាងសមត្ថភាព គ.ក.ន.ក ថ្នាក់ខេត្ត និងស្រុក និងតំណាងមន្ទីរជំនាញពាក់ព័ន្ធ ដែលនឹងទទួលបាននៅក្នុងវគ្គបណ្តុះបណ្តាលគ្រូបង្គោល។ ឯកសារនេះសំរាប់ជួយសំរួលគ្រូបង្គោលអោយទទួលបទពិសោធន៍ ពីរបៀបដែលត្រូវបណ្តុះបណ្តាលនៅថ្នាក់ឃុំ។ វាមានភាពខុសគ្នាសំខាន់មួយគឺ "ការពិនិត្យឯកសារឡើងវិញ" ដែលធ្វើឡើងបន្ទាប់ពីបញ្ចប់មេរៀននិមួយៗ។ គោលបំណងនៃការសង្ខេបពត៌មាននេះ ដើម្បីវាយតំលៃមេរៀន លើផ្នែកការពាក់ព័ន្ធដល់ឃុំ សកម្មភាព សំភារៈ និងការកំណត់ពេលវេលា។

## តួនាទីរបស់អ្នកសំរបសំរួល និងអ្នកមានធនធាន

នៅក្នុងវគ្គសិក្សានេះ និងមានវត្តមានរបស់ក្រុមអ្នកសំរបសំរួល និងអ្នកមានធនធាន ដែលមានតួនាទីខុសគ្នា ប៉ុន្តែបំពេញអោយគ្នាទៅវិញទៅមក ដើម្បីធានាថាសិក្ខាកាមបានរៀនសូត្រប្រកបដោយប្រសិទ្ធិភាព។ វាសំខាន់ណាស់ ដែលអ្នកសំរបសំរួលត្រូវធ្វើការពិភាក្សាខ្លីមួយជាមួយក្រុមការងារនេះ នៅមុនពេលដំណើរការវគ្គសិក្សា ដើម្បីវែកញែកពីតួនាទី របស់សមាជិកម្នាក់ៗដូចខាងក្រោម:

ទាំងអ្នកសំរបសំរួល និងអ្នកមានធនធានត្រូវចងចាំថា សិក្ខាកាមទាំងឡាយនឹងរៀនសូត្រ នៅពេលដែលគេចែករំលែកបទពិសោធន៍ និងគំនិតនៅក្នុងក្រុមតូចៗ។ នេះមានន័យថាតួនាទីរបស់អ្នកត្រូវស្ងៀមស្ងាត់ និងរង់ចាំ។ វាមិនមែនជាតួនាទីងាយស្រួលទេសំរាប់គ្រូបង្រៀន ឬអ្នកអនុវត្តន៍ត្រូវទទួលយក។ យើងត្រូវការអនុវត្តតួនាទីនេះ ដើម្បីទទួលយកនូវបទពិសោធន៍ពីការបង្រៀនរបៀបថ្មី។ យើងត្រូវការរៀនស្តាប់ អត់ធ្មត់ចំពោះតំរូវការផ្ទាល់ខ្លួនក្នុងការបង្រៀន និងផ្តល់ឱកាសអោយអ្នកចូលរួមបានរៀនសូត្រ។

*អ្នកសំរបសំរួល*

អ្នកសំរបសំរួលមានភារកិច្ចដូចខាងក្រោម:

- រៀបចំឯកសារ និងសំភារៈសំរាប់វគ្គសិក្សា
- ដឹកនាំ និងណែនាំគ្រប់សកម្មភាពដែលបានពិពណ៌នានៅគំរោងមេរៀនសំរាប់វគ្គសិក្សានេះ
- សំរបសំរួលការពិភាក្សាជាក្រុម
- ពិនិត្យសំភារៈ និងកំហុសឆ្គងក្នុងឯកសារ ដើម្បីផ្តល់ជាពត៌មានត្រឡប់ សំរាប់កែតំរូវឯកសារ
- វាយតំលៃសកម្មភាព និងផ្តល់ពត៌មានត្រឡប់ទៅអោយអ្នកធ្វើគំរោងកម្មវិធី នៅពេលបញ្ចប់វគ្គសិក្សា
- ផ្តល់គំនិតផ្សេងៗទៀតពីរបៀបពិនិត្យ និងកែលំអឯកសារសំរាប់វគ្គសិក្សា

*អ្នកមានធនធាន*

អ្នកមានធនធានមានភារកិច្ចដូចខាងក្រោម:

- ក្នុងកិច្ចសហការណ៍ជាមួយអ្នកសំរបសំរួល អ្នកមានធនធានត្រូវបញ្ជាក់អោយបានច្បាស់នូវរាល់ចំណុចទាក់ទងទៅនឹងពត៌មានផ្នែកបច្ចេកទេសនៅពេលចាំបាច់
- ពិនិត្យសំភារៈ និងកំហុសឆ្គងក្នុងឯកសារ ដើម្បីផ្តល់ជាពត៌មានត្រឡប់សំរាប់កែតំរូវឯកសារ
- ត្រួតពិនិត្យរាល់សកម្មភាព និងផ្តល់ពត៌មានត្រឡប់ទៅអោយអ្នកសំរបសំរួល នៅពេលបញ្ចប់មេរៀននិមួយៗ
- ផ្តល់គំនិតផ្សេងៗទៀតពីរបៀបពិនិត្យ និងកែសំរួលឯកសារសំរាប់វគ្គសិក្សា
- កត់ត្រានូវរាល់ការខ្វះចន្លោះចំណេះដឹងដើម្បីផ្តល់ជាដំណឹងទៅមន្ទីរអប់រំ។ (ឧទាហរណ៍ ប្រសិនបើ សិក្ខាកាមទំនងមិនអាចយល់ច្បាស់ពីផលប្រយោជន៍នៃការអប់រំកុមារក្នុងវ័យដំបូង មន្ទីរអប់រំអាចសំរេចដាក់បញ្ចូលបញ្ហានេះទៅក្នុងកម្មវិធីលើកកំពស់ការយល់ដឹងសាធារណៈរបស់មន្ទីរ)។

ផ្នែកដំបូងនេះនឹងបង្កលទ្ធភាពអោយគ្រូបង្គោល និងសិក្ខាកាមស្គាល់គ្នាទៅវិញទៅមក ដើម្បីអោយគ្រូបង្គោលអាចផ្តល់ព័ត៌មានដល់សិក្ខាកាម អំពីគោលបំណងនៃវគ្គបណ្តុះបណ្តាល និងដើម្បីអោយមានការឯកភាពលើវិន័យរួមរបស់ក្រុម។ ផ្នែកនេះមាន២មេរៀនដូចរាយនៅខាងក្រោម។ នៅមេរៀនទីមួយៗអ្នកនឹងឃើញគំរោងមេរៀន។



មេរៀនផ្នែកនេះមាន:

- គោលបំណង និងកម្មវិធីនៃវគ្គបណ្តុះបណ្តាល
- បង្កើតវិន័យក្រុម

សិក្ខាកាមភាគច្រើនចូលរួមទាំងភាពមិនច្បាស់លាស់ថា តើអ្នកណាជាគ្រូឧទ្ទេសនាម? តើគាត់រួសរាយរាក់ទាក់ និងបើកទូលាយអាចអោយសិក្ខាកាមមានយោបល់ដោយសេរីឬទេ? តើគាត់នឹងទទួលយកគំនិតរបស់សិក្ខាកាមឬទេ? ផ្នែកទី១នេះធ្វើអោយសិក្ខាកាមមានចំណាប់អារម្មណ៍លើស្ថានភាពជុំវិញខ្លួន ដែលគេអាចរំពឹងថា អាចកើតមានក្នុងកំឡុងពេលនៃវគ្គបណ្តុះបណ្តាល។ ប្រសិនបើការទាំងនេះដំណើរការបានល្អ នោះវានឹងផ្តល់បរិយាកាសងាយស្រួលធ្វើអោយសិក្ខាកាមចូលរួមចំណែកដោយសេរី និងយ៉ាងសកម្មក្នុងការពិភាក្សា និងចូលរួមធ្វើសកម្មភាពផ្សេងៗ ក្នុងវគ្គបណ្តុះបណ្តាលទាំងមូល។

# គោលបំណង និងវិន័យវគ្គសិក្សា

**គោលបំណង:** នៅចុងបញ្ចប់នៃមេរៀន សិក្ខាកាមនឹង

- អាចរៀបរាប់ពីគោលបំណងរបស់វគ្គសិក្សា
- ស្គាល់សមាជិកដែលចូលរួមបានយ៉ាងហោច៥០%
- មានវិន័យសំរាប់វគ្គសិក្សា



**រយៈពេល :** ប្រហែល៦០នាទី



**សំភារៈចាំបាច់ :** ប៊ិច និងក្រដាសសំរាប់កត់ត្រា ក្រដាស់ផ្ទាំងធំដែលបានសរសេរពីគោលបំណងរបស់វគ្គសិក្សា ឯកសារថតចំលងអំពីកម្មវិធី និងមេរៀនសំរាប់សិក្ខាកាមទី១.១ ទី១.២ និងទី១.៣។

**វិធីសាស្រ្ត :** ពិភាក្សាជាគូ និងពិភាក្សាពេញអង្គ

**របៀបសំរបសំរួលការបង្រៀន :**



១. សរសេរគោលបំណងមេរៀនលើក្រដាសផ្ទាំងធំ ឬលើក្ដារខៀន រួចអាន និងពន្យល់សិក្ខាកាមពី គោលបំណងទាំងនោះ។

២. ចែកមេរៀនទី១.១ ជូនសិក្ខាកាម“ស្វែងរកអ្នកណាដែល...” និងសុំអោយសិក្ខាកាមដើរក្នុងបន្ទប់មួយភ្លែត ដើម្បីបំពេញមេរៀនដែលចែកជូន។ វិន័យចំពោះសកម្មភាពនេះគឺសិក្ខាកាមមិនអាចអាចដាក់ឈ្មោះរបស់គាត់ផ្ទាល់ និងមិនអាចមានឈ្មោះច្រំដែល។ ប្រសិនបើចាំបាច់អ្នកសំរបសំរួលអាចអនុវត្តសកម្មភាពនេះ ដោយចោទសួរសំនួរទី១ទៅសិក្ខាកាមក្នុងថ្នាក់រហូតបានរកឃើញអ្នកដែលជាចំលើយសំរាប់សំនួរនេះ។

៣. បន្ទាប់ពីរយៈពេល៥នាទីកន្លងទៅ (មិនត្រូវទុកអោយសកម្មភាពនេះអូសបន្លាយពេលយូរពេកទេ)អានបញ្ជីមួយភ្លែត និងសួរសំនួរ។ ចំនាំ: ប្រសិន បើអ្នកសំរបសំរួលសួរថា “តើអ្នកណាដែលអ្នករកឃើញមានស្លាកកៅស៊ូ នៅក្នុងហោប៉ៅរបស់គាត់?” ប្រសិនបើចំលើយឆ្លើយថា“លោកគា” ដូច្នេះចំលើយត្រូវអ្នកដទៃទៀតនៅក្នុងក្រុមជាអ្នកឆ្លើយ។ ចោទសំនួរទៅសិក្ខាកាម

៤. បន្ទាប់មកសួរទៅសិក្ខាកាម៣-៤នាក់(ត្រូវមាននារីយ៉ាងតិច២នាក់) អំពីគោលបំណងរបស់ពួកគាត់ក្នុងការចូលរួមវគ្គសិក្សា។ មិនចាំបាច់កត់ត្រាទុកឡើយ។

៥. ថ្លែងអំណរគុណចំពោះមតិយោបល់របស់ពួកគាត់ និងបង្ហាញផ្ទាំងក្រដាសដែលបានសរសេរពីគោលបំណងវគ្គសិក្សា។ សង្កត់ធ្ងន់ថាវគ្គសិក្សានេះមិនមែនបណ្តុះបណ្តាលគាត់អោយក្លាយជាអ្នកជំនាញខាងផ្នែកអប់រំនោះទេ ប៉ុន្តែជាសំខាន់គឺ ជួយអោយពួកគាត់យល់ដឹងពីសារៈសំខាន់បញ្ហាចំបងៗ ដែលពាក់ព័ន្ធដល់ការអប់រំ និងពីរបៀបដែលពួកគាត់ត្រូវធ្វើការជាមួយមន្ទីរជំនាញពាក់ព័ន្ធ ដែលអាចអោយកូនៗរបស់យើងទាំងអស់គ្នាទទួលបាននូវសេវាអប់រំ។ ចំពោះអ្នកទាំងឡាយដែលនៅក្នុងក្រុមមិនបានយល់ដឹងពីតួនាទី និងភារកិច្ចរបស់ គ.ក.ន.ក សូមណែនាំពួកគាត់នូវឯកសារយោងដែល នៅខាងក្រោយបន្តពី ឯកសារមេរៀនសំរាប់សិក្ខាកាម។

៦. ជាបន្តបង្ហាញពីកម្មវិធី និងផ្តល់ពត៌មានសង្ខេបពីកាលវិភាគប្រចាំថ្ងៃ

៧. មុននឹងបញ្ចប់មេរៀន សូមអោយសិក្ខាកាមបង្កើតវិន័យសំរាប់វគ្គសិក្សា។

៨. សូមអោយសិក្ខាកាមគិតពីរបៀប ដែលគាត់ចង់ធ្វើការជាមួយគ្នា។ តើគាត់ចង់អោយអ្នកចូលរួមទាំងអស់មានអកប្បកិរិយា និងឥរិយាបទបែបណា? ផ្តល់ឧទាហរណ៍ខ្លះៗអោយគាត់ និងទុកពេលអោយគាត់គិតចំនួន១នាទី។

៩. សុំចំលើយ និងសរសេរចំលើយទាំងអស់នៅលើក្រដាសផ្ទាំងធំ

១០. ពិភាក្សាពីចំលើយ ដែលបានសរសេរលើក្រដាសផ្ទាំងធំ។ ព្រមព្រៀងជាមួយក្រុមការងារលើលទ្ធផលទទួលបាន និងពន្យល់ថាចំណុចមួយចំនួនអាចបញ្ចូលបន្ថែមនៅក្នុងដំណើរការវគ្គសិក្សា។ បិតក្រដាសផ្ទាំងធំលើជញ្ជាំង។

១១. រំលឹកសិក្ខាកាមថាទាំងអស់នេះជាវិន័យវគ្គបណ្តុះបណ្តាលដែលពួកគាត់បានព្រមព្រៀង។ ជំរុញអោយមានការគោរពវិន័យ និងបញ្ជាក់ថាពួកគាត់ត្រូវរួមចំណែកទទួលខុសត្រូវ ដើម្បីធានាអោយមានការគោរពវិន័យ។

# របនាសម្ព័ន្ធវគ្គសិក្សា

**គោលបំណង :** នៅចុងបញ្ចប់នៃមេរៀនសិក្ខាកាមអាច :

- អាចប្រើប្រាស់សំនួរដើម្បីធ្វើការដោះស្រាយបញ្ហាដែលកើតមានឡើង
- អាចពិពណ៌នាពីរបនាសម្ព័ន្ធវគ្គ



**រយៈពេល :** ប្រហែល៦០នាទី



**សំភារៈចាំបាច់ :** ប៊ិច និងក្រដាសសំរាប់កត់ត្រា ក្រដាសផ្ទាំងធំដែលបានសរសេរពីគោលបំណងវគ្គ និង មេរៀនសំរាប់សិក្ខាកាមទី១.២.១ ១.២.២ ១.២.៣ និង១.២.៤

**វិធីសាស្ត្រ :** ពិភាក្សាជាក្រុម ការពិភាក្សាពេញអង្គ និងការឡើងបង្ហាញ



**របៀបសំរបសំរួលការបង្រៀន :**

១. សរសេរគោលបំណងមេរៀនលើក្រដាសផ្ទាំងធំ ឬលើក្តារខៀន រួចអាន និងពន្យល់សិក្ខាកាមពីគោលបំណងទាំងនោះ ។

២. អនុវត្តន៍សកម្មភាពផ្តើកក្រុម ណែនាំសិក្ខាកាមនូវមេរៀនសំរាប់សិក្ខាកាមទី១.២.១ និងសុំអោយសិក្ខាកាមអានករណីសិក្សា និងពិភាក្សាពីសំនួរបើកចំនួន៤-មេរៀនសំរាប់សិក្ខាកាមទី១.២.២។ ក្រុមនិមួយៗត្រូវត្រៀមធ្វើការបង្ហាញពីចំលើយរបស់ក្រុមខ្លួនដល់ក្រុមធំ។ សង្កត់ធ្ងន់ថាការពិភាក្សារបស់ពួកគាត់ត្រូវផ្តោតទៅលើសុផារី ។

៣. ចាប់ផ្តើមពីសំនួរទី១ សុំមួយក្រុមអោយធ្វើការបង្ហាញចំលើយរបស់ក្រុមគាត់ និងក្រុមដទៃត្រូវស្តាប់ដោយយកចិត្តទុកដាក់ និងបន្ថែមចំណុចមួយចំនួនដែលគាត់មាន (ប្រសិនបើចំណុចដូចគ្នា គាត់មិនត្រូវបន្ថែមចំណុចច្រំដែល)។ សុំអោយអ្នកសំរបសំរួលម្នាក់ទៀតកត់ត្រានូវរាល់ចំលើយនៅលើក្រដាសផ្ទាំងធំ។ អនុវត្តសកម្មភាពដូចគ្នានេះចំពោះសំនួរទាំងបី ដែលនៅសល់។ ចំលើយចំពោះសំនួរចុងក្រោយនឹងជាផែនការសកម្មភាពសំរាប់ធ្វើការ អភិវឌ្ឍន៍ចំណេះដឹងផ្ទាល់ខ្លួនរបស់សុផារី។

៤. បន្ទាប់ពីការពិភាក្សា ពន្យល់សិក្ខាកាមថាតាមរយៈវគ្គសិក្សានេះ យើងនឹងប្រើប្រាស់សំនួរបើកចំនួន៤ ដើម្បីជួយយើងអោយពិពណ៌នាបញ្ហា វិភាគរកមូលហេតុបញ្ហា ពិចារណាពីផលប៉ះពាល់ និងពិនិត្យមើលដំណោះស្រាយបញ្ហា។ នៅក្នុងវគ្គសិក្សានេះទាំងមូលយើងនឹងពិនិត្យលើដំណោះស្រាយបញ្ហាដែលពាក់ព័ន្ធដល់ការអប់រំ ។

៥. ណែនាំសិក្ខាកាមនូវមេរៀនទី១.២.៣ ដែលផ្តល់នូវពត៌មានសង្ខេបពីរចនាសម្ព័ន្ធវគ្គ។ ទុកពេលខ្លះអោយសិក្ខាកាមអានរចនាសម្ព័ន្ធវគ្គ។ សុំអោយសិក្ខាកាមសួរ ប្រសិនបើគាត់មានសំនួរ។ ពេលដែលដំណើរការមានសារៈសំខាន់ក្នុងការធ្វើអោយសិក្ខាកាមចូលរួម និងយល់ច្បាស់ លទ្ធផលរំពឹងទុកសារៈសំខាន់បំផុតនៅក្នុងវគ្គសិក្សានេះគឺ ជំហានចុងក្រោយនៃផែនការសកម្មភាព។

៦. ចែកមេរៀនសំរាប់សិក្ខាកាមទី១.២.៤ ជូនសិក្ខាកាម-ផែនការសកម្មភាពសំរាប់ គ.ក.ន.ក និងពន្យល់ថានេះនឹងជាគោលបំណងរំពឹងទុកដ៏សំខាន់បំផុតរបស់វគ្គសិក្សាទាំងមូល។ នៅចុងបញ្ចប់វគ្គសិក្សានេះយើងនឹងបាននបញ្ជីផែនការសកម្មភាពមួយសំរាប់ គ.ក.ន.ក ដើម្បីបញ្ចូលទៅក្នុងផែនការសកម្មភាពប្រចាំខែរបស់គាត់។

## ផ្នែកទី២: ការអប់រំជាយុទ្ធសាស្ត្រមួយក្នុងការកាត់បន្ថយភាពក្រីក្រ

រាជរដ្ឋាភិបាលកម្ពុជាបានទទួលស្គាល់ថាការអភិវឌ្ឍន៍ផ្នែកអប់រំគឺជា សសរទ្រូងនៃយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្ររបស់ខ្លួន។ ការពង្រឹងផ្នែកអប់រំ និងប្រព័ន្ធបណ្តុះបណ្តាលគឺជាគន្លឹះក្នុងការបង្កើនការប្រកួតប្រជែងរបស់កម្ពុជានៅក្នុងការកើនឡើងនៃសេដ្ឋកិច្ចក្នុងតំបន់ និងលើសកលលោក។

ក្នុងផែនការអប់រំសំរាប់ទាំងអស់គ្នារបស់ក្រសួងអប់រំ មានបញ្ហាសំខាន់ពីរដែលត្រូវបានកំនត់ជាបញ្ហាគន្លឹះ។ ទី១គឺការបំពេញតំរូវការដោយពង្រីកលទ្ធភាពសេវាអប់រំអោយបានទូលំទូលាយ ជាពិសេសបង្កើនឱកាសទទួលបានការអប់រំនៅមធ្យមសិក្សាបឋមភូមិសំរាប់នារី។ ទី២គឺការលប់បំបាត់ការបង់ថ្លៃសាលាសំរាប់ការអប់រំនៅបឋមសិក្សា និងមធ្យមសិក្សា។

នៅក្នុងគំរោងរបស់ខ្លួនក្រសួងអប់រំ បានតំរូវអោយថ្នាក់ឃុំសំរេចផែនការអនុវត្តន៍ទៅលើ៦ផ្នែកសំខាន់ៗ:

- ការថែទាំ និងអភិវឌ្ឍន៍កុមារក្នុងវ័យដំបូង (ECCD )
- ការអប់រំជាមូលដ្ឋានក្នុងប្រព័ន្ធ
- ការអប់រំក្រៅប្រព័ន្ធ និងបណ្តុះបណ្តាលជំនាញបំនិនជីវិត
- សមភាពផ្នែកយេន័រ
- គុណភាពការអប់រំ
- ទទួលនូវសេវាអប់រំជំនាញបំនិនជីវិត

នៅក្នុងឯកសារពង្រាងច្បាប់អប់រំបានបញ្ជាក់ថា ក្រុមប្រឹក្សាឃុំនិងសហការណ៍ជាមួយក្រសួង ដើម្បីអភិវឌ្ឍន៍គ្រប់ទិដ្ឋភាពការអប់រំ។ នេះជាការពិតទោះជាមិនទាន់មានការកំណត់តួនាទីអោយបានជាក់លាក់ក៏ដោយ។

យ៉ាងណាក៏ដោយ យើងអាចរំពឹងទុកថាក្រុមប្រឹក្សាឃុំ និងគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំនឹងអនុវត្តតួនាទីគាំទ្រ និងស្វែងរកមតិគាំទ្រសំរាប់សេវា:

មត្តេយ្យសហគមន៍ និងការចូលរៀនរបស់កុមារនៅអាយុ៦ឆ្នាំ ជាពិសេសកុមារី

ការបញ្ចប់ថ្នាក់បឋមសិក្សាជាពិសេសចំពោះកុមារដែលបានចូលរៀន

ថ្នាក់អក្ខរកម្មសំរាប់កុមារដែលមិនបានចូលរៀននៅសាលា។

ស្ថិតិឆ្នាំ២០០០ ស្តីពី ស្ថានភាពកុមារនៅលើពិភពលោក

| *សូចនាករណ៍* | *ប្រុស* | *នារី* |
|---|---|---|
| *អត្រាអក្ខរកម្មមនុស្សពេញវ័យ* | *៨០%* | *៥៧%* |
| *ចូលរៀននៅបឋមសិក្សា* | ១០០% | *៩០%* |
| *%កុមារចូលរៀនបឋមសិក្សាបន្តដល់ថ្នាក់ទី៥* | *៦៣% (ទាំងស្រីទាំងប្រុស)* | |

វាត្រូវបានរំពឹងថា ដោយមានការគាំទ្រ និងជំនួយបច្ចេកទេសរបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ ក្រុមប្រឹក្សាឃុំនឹងយល់ដឹងពីបញ្ហានៅក្នុងដៃ និងច្បាស់លាស់ពីអ្វី ដែលពួកគាត់ត្រូវអនុវត្ត ដើម្បីជួយដោះស្រាយបញ្ហា និងត្រូវដោះស្រាយយ៉ាងដូចម្តេច ។

**ផ្នែកនេះមានគំរោងមេរៀនដូចខាងក្រោមៈ**

- ការថែទាំ និងអភិវឌ្ឍន៍កុមារក្នុងវ័យដំបូង (ECCD )
- ការអប់រំជាមូលដ្ឋានក្នុងប្រព័ន្ធ
- ថ្នាក់អក្ខរកម្ម

# ការអប់រំដែលជាយុទ្ធសាស្ត្រមួយក្នុងការកាត់បន្ថយភាពក្រីក្រ

**គោលបំណង :** នៅចុងបញ្ចប់នៃមេរៀនសិក្ខាកាមអាច :

- រៀបរាប់ពីផលប្រយោជន៍នៃការអប់រំ
- ប្តេជ្ញាធ្វើការលើកកំពស់ស្ថានភាពអក្ខរកម្មអោយទៅជាអាទិភាពរបស់ គ.ក.ន.ក



**រយៈពេល :** ប្រហែល៦០នាទី



**សំភារៈចាំបាច់ :** ក្រដាសផ្ទាំងធំ និងហ្វឺត ប័ណ្ណចំនួន៦សម្រាប់ជាភាសាខ្មែរ ត្រៀមសំរាប់លំហាត់ភ្ជាប់បំណែក ប័ណ្ណចំនួន៦សម្រាប់ ដែលសរសេរជាភាសាបរទេសផ្សេងៗពីគ្នា

**វិធីសាស្ត្រ :** ការបំផុសគំនិត ពិភាក្សាជាក្រុម និងការឡើងបង្ហាញ



**របៀបសំរបសំរួលការបង្រៀន :**

១. សរសេរគោលបំណងមេរៀនលើក្រដាសផ្ទាំងធំ ឬលើក្តារខៀន រួចអាន និងពន្យល់សិក្ខាកាមពីគោលបំណងទាំងនោះ។

២. ចែកសិក្ខាកាមពិភាក្សាជា៦ក្រុម និងចែកស្រោមសំបុត្រមួយ (ប័ណ្ណមួយសម្រាប់ជាភាសាចិន ហ្វាងឡង់ ហូឡង់) សំរាប់១ក្រុមពន្យល់ថា "មានប្រធានបទ៣ស្តីពីស្ថានភាពការអប់រំនៅក្នុងប្រទេសកម្ពុជា ប៉ុន្តែត្រូវកាត់ចេញជាបំណែកៗខូចន័យសេចក្តីពេញលេញរបស់ប្រធានបទទាំងនេះ ការងាររបស់អ្នកគឺត្រូវភ្ជាប់ប័ណ្ណទាំងនេះតាមលំដាប់ និងទៅតាមន័យសេចក្តីត្រឹមត្រូវ"។ ៣នាទីបន្ទាប់មក ប្រសិនបើសិក្ខាកាមទំនងថាមិនអាចធ្វើកិច្ចការនេះបានទេ អ្នកត្រូវប្រមូលប័ណ្ណមកវិញ និងចែកស្រោមសំបុត្រមួយថ្មីអោយគាត់ ប័ណ្ណដែលចែកអោយលើកនេះសរសេរជាភាសាខ្មែរ។ អនុវត្តសកម្មភាពដូចមុន។

៣. ទុកពេលអោយគាត់៥នាទី ដើម្បីភ្ជាប់បំណែកទាំងនេះទៅតាមលំដាប់លំដោយ ដែលមានន័យសេចក្តីត្រឹមត្រូវ។

ចំលើយមាន : បុរសកម្ពុជា៨នាក់ក្នុងចំណោម១០នាក់ចេះអាន និងសរសេរ។ ស្ត្រីកម្ពុជា៥,៧នាក់ក្នុងចំណោម១០នាក់ចេះអាន និងសរសេរ។ ប្រជាជនកម្ពុជា១.៥លាននាក់ជាអនក្ខរជន។ បន្ទាប់ពីបានចំលើយ សុំអោយអ្នកស្ម័គ្រចិត្តឡើងអានប្រធានបទទាំងនោះខ្លាំងៗ។

៤. សួរគាត់ថា តើគាត់គិតយ៉ាងណាពីស្ថិតិទាំងនេះ? តើគាត់មានអារម្មណ៍យ៉ាងណាចំពោះស្ថិតិនេះ?

៥. តើអ្នកមានអារម្មណ៍យ៉ាងណា នៅពេលដែលអ្នកមិនចេះអាន អ្វីដែលបានសរសេរលើបណ្ណដែលចែកអោយពីដំបូង? តើបញ្ហាអ្វីខ្លះដែលអនក្ខរជនជួបប្រទះ? ពិភាក្សារកចំលើយនៅក្នុងក្រុមធំ និងកត់ត្រាចំលើយលើក្រដាសផ្ទាំងធំ

៦. តើអ្វីជា"ការចេះអាន និងសរសេរ"? សួរសិក្ខាកាមថា តើគាត់មានអារម្មណ៍យ៉ាងណាចំពោះការចេះអាន និងសរសេរ? តើយើងអាចធ្វើអ្វីខ្លះពីការចេះអាន និងសរសេរ? តើវាមានប្រយោជន៍អ្វី

សំរាប់មនុស្សម្នាក់ៗ?

ចំលើយអាចមាន :

- អាចអានផ្លាកមុខទំនិញនៅលើដប ឬកំប៉ុង
- អាចអានក្រដាសផ្ទត់ដែលគេចែកអោយ
- អាចអានសារពត៌មាន
- អាចគិតលុយ និងចំនួនអោយបានត្រឹមត្រូវ
- អាចមានការងារផ្សេងក្រៅពីធ្វើស្រែ
- អាចធ្វើសេចក្តីសំរេចដ៏ឈ្លាសវៃ
- អាចយល់ពីសារៈសំខាន់គំរោង និងកម្មវិធីមួយចំនួន
- អាចរិះរកពីវិធីជួយខ្លួនឯង
- អាចចូលរួមយ៉ាងសកម្មនៅក្នុងសកម្មភាពសហគមន៍
- អាចឈរឈ្មោះអោយគេបោះឆ្នោតធ្វើជាសមាជិកក្រុមប្រឹក្សាឃុំ
- មានអារម្មណ៍ល្អចំពោះខ្លួនឯង
- គិតថាខ្លួនឯងជាមនុស្សមានប្រយោជន៍

*ឪពុកម្តាយដែលជាអក្ខរជនជំរុញយ៉ាងខ្លាំងក្លាដើម្បីអោយកូនៗរបស់គេក្លាយជាអក្ខរជន*

៧. ជាអក្ខរជន និងចេះលេខនព្វន្ត ផ្តល់អោយយើងនូវជំរើសបន្ថែមទៀត។ ការធានាថា កូនៗរបស់យើងទាំងស្រីទាំងប្រុសទទួលបានការអប់រំ និង បានបញ្ចប់ការសិក្សាក្នុងរយៈពេល៦ឆ្នាំ ដែលអាចកំណត់ពីអនាគតប្រទេសរបស់យើង។ ពន្យល់ថាការអប់រំគឺជា ឱកាសសំរាប់ធ្វើការអភិវឌ្ឍន៍ចំណេះដឹងផ្ទាល់ខ្លួន និងសំរាប់អនាគតដ៏ប្រពៃហើយនៅក្នុងរដ្ឋធម្មនុញ្ញរបស់ប្រទេសកម្ពុជា បានកំនត់ផ្តល់អោយប្រជាជនខ្មែរគ្រប់រូបទទួលបានការអប់រំដោយឥតបង់ថ្លៃរយៈពេល ៩ឆ្នាំនៅតាមសាលារដ្ឋ។

៨. សុំអោយសិក្ខាកាមធ្វើការជាក្រុមមានសមាជិក៣នាក់ និងចែក post-it ៣សន្លឹកអោយពួកគាត់។ សុំអោយសិក្ខាកាមពិភាក្សាពី បញ្ហាបន្ទាន់ចំនួន៣ទាក់ទងទៅដល់ការអប់រំនៅក្នុងសហគមន៍របស់គាត់។

៩. សុំអោយសិក្ខាកាមបិទចំលើយលើក្តារខៀន។ អ្នកសំរបសំរួលអាចបែងចែកចំលើយទាំងនោះទៅតាមៈ ការថែទាំ និងអភិវឌ្ឍន៍កុមារក្នុងវ័យដំបូង (ECCD )ការអប់រំផាមូលដ្ឋានក្នុង ប្រព័ន្ធ និងការអប់រំក្រៅប្រព័ន្ធ។ ជំរុញអោយសិក្ខាកាមដើរទៅមើលពីបញ្ហា ដែលអ្នកដទៃជួបប្រទះនៅក្នុងឃុំរបស់គេ។ សង្ខេបចំលើយដែលបានពីក្រុមនិមួយៗ និងសរសេរបញ្ហាចំបងៗនៅលើក្រដាសផ្ទាំង។ ពិនិត្យអោយដឹងថាតើបញ្ហាទាំងនេះឆ្លើយតបនិង ប្រធានបទដែលយើងពិភាក្សានៅក្នុងវគ្គសិក្សានេះយ៉ាងដូម្តេច?

១០. ពន្យល់សិក្ខាកាមថា ក្នុងវគ្គនេះ យើងចង់អោយពួកគាត់គិតពីអ្វីដែលសហគមន៍ និងអ្នកដឹកនាំសហគមន៍(ក្រុមប្រឹក្សាឃុំ គ.ក.ឧ.ក គណៈកម្មាធិការផែនការ និងថវិកា និងអ្នកតំណាងភូមិ)ត្រូវអនុវត្ត ដើម្បីធានាថាកូនៗរបស់យើងទទួលបានការអប់រំដែលអាចអោយពួកគេសំរេចបានយ៉ាងពេញលេញនូវសក្តានុពលរបស់គេ។

១១. ក្នុងនាមជាគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ អ្នកអាចធ្វើអោយមានភាពខុសប្លែក ដោយអនុវត្តជំហានពិសេសដែលយើងនិងឃើញនៅក្នុងពីរថ្ងៃទៀត។ ដំបូងអ្នកត្រូវមានគំនិត/ឥរិយាបទថា ខ្ញុំអាចធ្វើបាន។ បន្ទាប់មកទៀតយើងនិងមើលទៅលើចំណេះដឹង និងជំនាញ ដែលអ្នកត្រូវការ និងក្រោយពីពេលនេះកន្លងទៅយើងសង្ឃឹមថា វានឹងក្លាយទៅជាទំលាប់។ មេរៀនសំរាប់សិក្ខាកាមទី២.១

# ផ្នែកទី៣: ការថែទាំ និងអភិវឌ្ឍន៍កុមារភាពក្នុងវ័យដំបូង

**គោលបំណង :** នៅចុងបញ្ចប់នៃមេរៀនសិក្ខាកាមអាច :

-រៀបរាប់ពីសារៈសំខាន់នៃការថែទាំ និងអភិវឌ្ឍន៍កុមារក្នុងវ័យដំបូង និងផលប៉ះពាល់របស់វាទៅលើអនាគតរបស់កុមារ ។

-បង្កើតសកម្មភាពជាជំហានៗមួយចំនួន ស្ដីពី អ្វីដែលគាត់អាចអនុវត្ត ដើម្បីជំរុញ និងបង្កើតអោយមានសេវាថែទាំកុមារតូច និងមត្តេយ្យសិក្សាសំរាប់កុមារអាយុពី៣-៥ឆ្នាំនៅក្នុងឃុំ



**រយៈពេល :** ប្រហែល៦០នាទី



**សំភារៈចាំបាច់ :** ករណីសិក្សាទី១ (ការថែទាំ និងអភិវឌ្ឍន៍កុមារក្នុងវ័យដំបូង ECCD ) ក្រដាសផ្ទាំងធំ និងហ្វឺត មេរៀនសំរាប់សិក្ខាកាមទី៣.១

**វិធីសាស្ត្រ :** ករណីសិក្សា ការបំផុសគំនិត ពិភាក្សាជាក្រុម និងការឡើងបង្ហាញ ខ្សែវីដេអូ ឬផ្ទាំងរូបភាព ស្ដីពី ECCD



**របៀបសំរបសំរួលការបង្រៀន :**

១. សរសេរគោលបំណងមេរៀនលើក្រដាសផ្ទាំងធំ ឬលើក្តារខៀន រួចអាន និងពន្យល់សិក្ខាកាមពីគោលបំណងទាំងនោះ ។

២. សួរសិក្ខាកាមថា តើនៅក្នុងចំណោមពួកគាត់មានប៉ុន្មាននាក់មានកូនអាយុពី០-៦ឆ្នាំ បន្ទាប់មកទៀតសួរថា ជារៀងរាល់ថ្ងៃ តើក្មេងទាំងនោះធ្វើអ្វីខ្លះ?

ចំលើយអាចមាន :

- នៅផ្ទះជាមួយម្តាយ ឬជីដូន
- នៅផ្ទះជាមួយបង ឬសាច់ញាតិ
- ទៅរៀននៅមត្តេយ្យសហគមន៍ ឬមណ្ឌលថែទាំកុមារតូចដែលមានមូលដ្ឋាននៅតាមផ្ទះ

៣. សង្កត់ធ្ងន់ថា ជាការពិត យើងដឹងថា អន្តរាគមន៍ពីដំបូងទៅលើវ័យដំបូងរបស់កុមារមានអត្ថប្រយោជន៍ និងមានផលប៉ះពាល់ឥតឈប់ឈរទៅលើកុមារ ការអភិវឌ្ឍន៍ផ្នែកខួរក្បាលយ៉ាងឆាប់រហ័ស នៅក្នុងខែ និងឆ្នាំដំបូង។ កង្វះការយកចិត្តទុកដាក់គឺ ខូចខាតលើសពីអ្វីដែលយើងបានគិតទុកជាមុន ។

៤. ប្រាប់ទៅសិក្ខាកាមថាពេលនេះអ្នកនឹងបង្ហាញខ្សែវីដេអូ ឬផ្ទាំងរូបភាព ស្តីពីសារៈសំខាន់ការថែទាំ និងអភិវឌ្ឍន៍កុមារវ័យដំបូង និងសុំអោយពួកគាត់ពិនិត្យមើលពីអ្វីដែលពួកគាត់អាចរៀនសូត្រពីខ្សែវីដេអូ ឬរូបភាពទាំងនេះ។ សង្ខេបអត្ថន័យផ្ទាំងរូបភាព ដោយចែកមេរៀនសំរាប់សិក្ខាកាមទី៣.១ៈ តើអ្វីដែលអ្នកអាចអនុវត្តសំរាប់កុមារអាយុពី០-៣ឆ្នាំ ដើម្បីជួយដល់ការអភិវឌ្ឍន៍របស់គេ?

- ការអភិវឌ្ឍន៍ធ្វើឡើងតាំងពីពេលចាប់កំណើត
- កុមារត្រូវការនូវការយកចិត្តទុកដាក់
- កុមារត្រូវការនូវទំនាក់ទំនង

៥. ហេតុអ្វីអ្នកត្រូវនាំកូនរបស់អ្នកទៅរៀននៅថ្នាក់មត្តេយ្យ? វាមានចំណុចសំខាន់៣ដែលយើងត្រូវសង្កត់ធ្ងន់ទៅលើឪពុកម្តាយ ដូចជាផ្នែកមួយនៃការស្វែងរកមតិគាំទ្រ។ បន្ទាប់ពីការពិភាក្សាចែកមេរៀនទី៣.២។

៦. ចែកសិក្ខាកាមជា៥ ឬ៦ក្រុម ដោយលេងល្បែងសំរាប់បង្កើតក្រុម។ ឧទាហរណ៍ ប្រសិនបើមានសិក្ខាកាមចំនួន២៥នាក់កំណត់រកអ្នក ដែលអានបានល្អចំនួន៥នាក់ហើយអោយពួកគាត់ទៅនៅជ្រុងម្ខាងនៃបន្ទប់។ ពន្យល់ថា ពួកគាត់ជាអ្នកដឹកនាំក្រុមទាំង៥ ហើយការងាររបស់អ្នកនៅសល់ទាំង២០នាក់នោះគឺត្រូវជ្រើសរើសក្រុមណាមួយដើម្បីចូលរួម។ មានលក្ខខ័ណ្ឌ២ៈ ក្នុង១ក្រុមៗមិនត្រូវមានសមាជិកច្រើនជាង៦នាក់ និងក្រុមដទៃមិនត្រូវមានសមាជិកតិចជាង៥នាក់។

៧. សុំអោយសិក្ខាកាមចូលតាមក្រុមតូចៗរបស់គាត់ និងពន្យល់ថា ពេលនេះគាត់មានតួនាទីជាសមាជិកក្រុមប្រឹក្សាឃុំ ឬ គ.ក.ន.ក ឬគណៈកម្មាធិការផែនការ និងថវិកា។ សុំអោយគាត់ពិចារណាពីសេវាអប់រំ ឬថែទាំកុមារភាពក្នុងវ័យដំបូងដែលមាននៅក្នុងឃុំ។ ប្រសិនបើគ្មាន តើដោយសារមូលហេតុអ្វី? តើអ្វីដែល គ.ក.ន.ក អាចធ្វើអ្វី ដើម្បីគាំទ្រប្រជាជន? កត់ត្រាចំលើយលើក្រដាសផ្ទាំងធំ។

ចំលើយចំពោះការមិនបញ្ជូនកូនអោយទៅរៀនមានៈ

-គ្រួសារក្រីក្រ

-ទុកកូនចោលពេញមួយថ្ងៃដោយសារគ្រប់គ្នានៅក្នុងគ្រួសារជាប់រវល់ធ្វើការងារខ្លាំងពេក

-កុមារនៅក្មេងពេកមិនអាចទៅសាលារៀនបាន

-មិនយល់ពីសារៈប្រយោជន៍ការអប់រំកុមារភាពក្នុងវ័យដំបូង

-មត្តេយ្យសហគមន៍និងថ្នាក់ថែទាំកុមារតូចដែលមានមូលដ្ឋាននៅតាមផ្ទះមិនឃើញមានបង្រៀនអ្វីសោះ-គ្មានទំនុកចិត្តលើគ្រូមត្តេយ្យ

-ខ្វះការផ្សព្វផ្សាយពីសារៈប្រយោជន៍នៃការអប់រំកុមារភាពក្នុងវ័យដំបូង

សកម្មភាពត្រូវអនុវត្ត ៖

-បង្កើតអោយមានឥណទាន និងមូលនិធិ

-ជំរុញអោយឪពុកម្តាយ អាណាព្យាបាលនាំកុមារទៅសាលារៀន

-ផ្សព្វផ្សាយពីសារៈប្រយោជន៍នៃការអប់រំកុមារក្នុងវ័យដំបូង

-ផ្សព្វផ្សាយពីសារៈប្រយោជន៍មត្តេយ្យសហគមន៍

-បំប៉នគ្រូមត្តេយ្យសហគមន៍អោយមានសមត្ថភាពខ្ពស់ក្នុងការបង្រៀន

៨. នៅលើក្រដាសផ្ទាំងធំបង្កើតតារាងដូចគ្នា និងបូកសរុបចំលើយរបស់សិក្ខាកាម។ សកម្មភាពទាំងនេះនឹងត្រូវទុកជាផែនការសកម្មភាព សំរាប់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ។

# ផ្នែកទី៤: ការអប់រំជាមូលដ្ឋាន ក្នុងប្រព័ន្ធ

**គោលបំណង** : នៅចុងបញ្ចប់នៃមេរៀនសិក្ខាកាមអាច :

- កំណត់ផលប្រយោជន៍នៃការទៅរៀនទៀងទាត់ និងផលប៉ះពាល់របស់វាចំពោះឱកាសដែលអាចអោយកុមាររៀនបានយ៉ាងល្អប្រសើរនៅក្នុងសាលារៀន
- បង្កើតសកម្មភាពជាជំហាន៧ពីអ្វីដែល គ.ក.ឧ.ក និងអ្នកតំណាងភូមិអាចអនុវត្ត ដើម្បីជួយដោះស្រាយបញ្ហា និងលើកបញ្ហាទាំងនេះជាអាទិភាព នៅក្នុងដំណើរការកសាងផែនការឃុំ។



**រយៈពេល** : ប្រហែល៦០នាទី



**សំភារៈចាំបាច់** : ក្រដាសផ្ទាំងធំ និងហ្វឺត មេរៀនសំរាប់សិក្ខាកាមទី៤.១

**វិធីសាស្ត្រ** : ករណីសិក្សា ការបំផុសគំនិត ពិភាក្សាជាក្រុម និងការឡើងបង្ហាញ

**របៀបសំរបសំរួលការបង្រៀន** :



១. សរសេរគោលបំណងមេរៀនលើក្រដាសផ្ទាំងធំ ឬលើក្តារខៀន រួចអាន និងពន្យល់សិក្ខាកាមពីគោលបំណងទាំងនោះ។

២. ក្នុងការពិភាក្សាពេញអង្គ សួរសិក្ខាកាមថា“តើអ្វីជាការអប់រំជាមូលដ្ឋានក្នុងប្រព័ន្ធ?”“តើកុមារមានសិទ្ធិអ្វីខ្លះពាក់ព័ន្ធជាមួយការអប់រំជាមូលដ្ឋានក្នុងប្រព័ន្ធ?”

៣. នៅក្នុងការពិភាក្សាជាគូ សួរទៅសិក្ខាកាមថា“តើនៅក្នុងឃុំរបស់ពួកគាត់មានបញ្ហាអ្វីខ្លះដែលប៉ះពាល់ដល់ការអប់រំជាមូលដ្ឋានក្នុងប្រព័ន្ធ?”

ចំលើយអាចមាន :

- កុមារមានអាយុ៦ឆ្នាំនៅក្នុងឃុំមិនបានទៅសាលារៀនថ្នាក់បឋមសិក្សាបានគ្រប់គ្នា (ទាក់ទងនិងចំណុចទី៧ នៃកញ្ចប់គតិមានសំរាប់អ្នកដឹកនាំ)
- កុមារទើបនឹងកើតជាច្រើន មិនបានចុះបញ្ជីកំណើត ដែលធ្វើអោយមេភូមិជួបការលំបាកក្នុងការតាមដាន
- កុមារា និងកុមារីជាច្រើននាក់មិនបានបញ្ចប់បឋមសិក្សា
- សាលារៀនស្ថិតនៅឆ្ងាយពីភូមិ
- ស្អួនកំសាន្តសំរាប់កុមារនៅក្នុងសាលា និងទ្រព្យសម្បត្តិរបស់សាលារៀនគ្មានការថែទាំ

- ក្នុងសាលារៀនគ្មានទឹកស្អាតគ្រប់គ្រាន់ គ្មានអណ្ដូងទឹក និងគ្មានបង្គន់អនាម័យ

៤. ចែកសិក្ខាកាមជាក្រុមមានសមាជិក៥/៦នាក់ និងសុំអោយពួកគាត់អានមេរៀនសំរាប់សិក្ខាកាមទី៤.១។ ពន្យល់សិក្ខាកាមថា នៅក្នុងក្រុមរបស់អ្នក សូមធ្វើការវិភាគពីស្ថានភាព ដោយអនុវត្តតាមតារាងមាំទ្រិច។ ចូរចងចាំថា ដំណោះស្រាយនឹងត្រូវជាសកម្មភាព ដែល គ.ក.ន.ក និងតំណាងភូមិអាចអនុវត្ត។

ចំលើយអាចមាន:

- ឆ្ងាយដាច់ស្រយាល-មិនអាចទៅសាលារៀន
- ពួកគេត្រូវអោយធ្វើការ-ចិញ្ចឹមជីវិតដោយឃ្វៀលគោ ឬលក់ផ្កា
- ធ្វើការងារជាមួយឪពុកម្ដាយនៅតាមស្រែចំការ ឬនៅក្នុងព្រៃ
- ពួកគេត្រូវអោយថែទាំប្អូនៗ
- កុមារខ្វះចំណីអាហារ ហេតុនេះនៅតែផ្ទះ

ដំណោះស្រាយមាន:

- សុំអោយមេភូមិប្រមូលពត៌មានពីចំនួនកុមារនៅក្នុងភូមិដែលមិនចុះឈ្មោះចូលរៀន និងទៅសួរសុខទុក្ខគ្រួសារទាំងនោះ ដើម្បីរកអោយឃើញមូលហេតុដែលធ្វើអោយកុមារ ដែលមានអាយុ៦ឆ្នាំមិនបានចុះឈ្មោះចូលរៀន។
- ផ្សព្វផ្សាយពីសារៈសំខាន់នៃការទៅរៀនទៀងទាត់ តាមរយៈការប្រើប្រាស់រឿង ដែលមាន ជោគជ័យ។
- វិនិយោគលើមធ្យោបាយធ្វើដំណើរក្នុងភូមិ (រ៉ឺម៉កសាលារៀន/ភូមិ) ដើម្បីដឹកជញ្ជូនកុមារនៅតំបន់ឆ្ងាយដាច់ស្រយាលទៅ និងត្រឡប់ពីសាលារៀន។
- ជំរុញកុមារអោយយល់ពី អត្តន័យភាពជាម្ចាស់សាលារៀន និងបរិស្ថានជុំវិញបរិវេណសាលា តាមរយៈយុទ្ធនាការ ការប្រឡងប្រណាំង និងការទទួលខុសត្រូវសំអាតថ្នាក់រៀនតាមវេណ។
- ការលើកកំពស់ការប្រើប្រាស់ និងការថែទាំប្រភពទឹកស្អាត និងបង្គន់ក្នុងសាលារៀន។
- សង្កត់ធ្ងន់ទៅលើសារៈសំខាន់ទឹកស្អាត និងអនាម័យចំពោះសុខភាពកុមារ និងអត្រាចូលរៀនរបស់កុមារី។
- ជំនួយឧបត្ថម្ភសំរាប់គ្រួសារក្រីក្រ

៥. សរុបចំលើយរបស់សិក្ខាកាមនៅលើក្រដាសផ្ទាំងធំ ហើយសកម្មភាពទាំងនេះត្រូវបញ្ចូលជាផែនការសកម្មភាពសំរាប់ គ.ក.ន.ក (មេរៀនសំរាប់សិក្ខាកាមទី១.៤)។

# ផ្នែកទី៥: ថ្នាក់អក្ខរកម្ម

**គោលបំណង** : នៅចុងបញ្ចប់នៃមេរៀនសិក្ខាកាមអាច :

- រៀបរាប់ពីមនុស្សក្នុងឃុំ ដែលនឹងទទួលផលប្រយោជន៍ពីថ្នាក់អក្ខរកម្ម
- រៀបរាប់ពីជំហាន ដែលត្រូវអនុវត្ត ដើម្បីកែលំអស្ថានភាពអក្ខរកម្មនៅក្នុងឃុំអោយកាន់តែប្រសើរ



**រយៈពេល** : ប្រហែល៤៥នាទី



**សំភារៈចាំបាច់** : មេរៀនសំរាប់សិក្ខាកាមទី៥.១ និង៥.២-ករណីសិក្សា

**វិធីសាស្រ្ត** : ការបំផុសគំនិត ពិភាក្សាជាគូ និងពិភាក្សាជាក្រុម



**របៀបសំរបសំរួលការបង្រៀន** :

១. សរសេរគោលបំណងមេរៀនលើក្រដាសផ្ទាំងធំ ឬលើក្តារខៀនរួចអាន និងពន្យល់សិក្ខាកាមពីគោលបំណងទាំងនោះ។

២. បែងចែកសិក្ខាកាមជាក្រុមមានសមាជិក៣នាក់ និងសុំអោយគាត់អានករណីសិក្សា។ បន្ទាប់មកពន្យល់សិក្ខាកាមក្នុងក្រុមដែលស្ថិតនៅម្ខាងនៃបន្ទប់ថា ពួកគាត់ត្រូវគិតថាគាត់ជាកុមារា និងកុមារីនៅក្នុងករណីសិក្សា ហើយសូមអោយពួកគាត់ពិភាក្សាពីមូលហេតុ ដែលកុមារទាំងនោះមិនទៅរៀន។ ពន្យល់ក្រុមដែលនៅម្ខាងទៀតថា ពួកគាត់គឺជា សមាជិក គ.ក.ន.ក តើពួកគាត់ត្រូវធ្វើអ្វីខ្លះដើម្បីជួយកុមារទាំងនេះ។ មេរៀនសំរាប់សិក្ខាកាមទី....

៣. សុំអោយសិក្ខាកាមធ្វើការសន្ទនាតូចមួយ ដោយមានមួយក្រុមជាអ្នកផ្តល់នូវឬសគល់បញ្ហា និងមួយក្រុមទៀតឆ្លើយនូវដំណោះស្រាយសមស្រប។ បន្តធ្វើសកម្មភាពរហូតបានពិភាក្សាលើគ្រប់ឫសគល់បញ្ហាដែលបានផ្តល់។

៤. បញ្ជាក់ថាយើងទាំងអស់គ្នាបានយល់ស្របពីសារៈសំខាន់ការអប់រំសំរាប់ទាំងអស់គ្នា-មិនមែនសំរាប់តែកុមារអាយុ៦ឆ្នាំទេ គឺត្រូវតែគិតដល់កុមារដែលមានអាយុលើសពី៦ឆ្នាំ តើត្រូវធ្វើអ្វីសំរាប់ពួកគេ?

៥. សង្ខេបលទ្ធផលការពិភាក្សា ដោយកត់ត្រាមូលហេតុដែលបានពីក្រុមក និងដំណោះស្រាយដែលបានពីក្រុមខ នៅក្នុងតារាងមាទ្រិច។



**កំណត់ចំណាំសំរាប់អ្នកសំរបសំរួល:**

គោលបំណងរបស់ក្រសួងអប់រំចំពោះការអប់រំក្រៅប្រព័ន្ធគឺ :

- បង្កលក្ខណៈអោយកុមារអាយុពី៧-១២ឆ្នាំចូលរួមក្នុងការអប់រំជាមូលដ្ឋានជាថ្មី-កម្មវិធីចុះឈ្មោះចូលរៀនជាថ្មី
- ដើម្បីជួយសំរួលអោយក្មេងជំទង់ ១២-១៥ឆ្នាំ ទទួលបានការអប់រំជាមូលដ្ឋានសមមូល
- ជំរុញអោយយុវជនដែលមិនបានទៅសាលារៀនអោយចេះអាន និងចេះសរសេរ និងបានអភិវឌ្ឍន៍ជំនាញបំណិនជីវិត និងសមត្ថភាពក្នុងការងារដោយរួមបញ្ចូលទាំងជំនាញក្នុងការធ្វើជាឪពុកម្តាយ និងការបណ្តុះបណ្តាលវិជ្ជាជីវៈ។
- ដំណើរការថ្នាក់អក្ខរកម្ម ក្នុងការជំរុញឥរិយាបទ ចំណេះដឹង និងជំនាញចាំបាច់សំរាប់រៀបចំជីវិត និងការងារ

# ថ្នាក់អក្ខរកម្ម

**គោលបំណង** : នៅចុងបញ្ចប់នៃមេរៀនសិក្ខាកាមអាច :

- រៀបរាប់ពីមធ្យោបាយជំរុញអោយប្រជាជនក្នុងភូមិចូលរៀនអក្ខរកម្ម
- រៀបរាប់ពីមធ្យោបាយ ដើម្បីធានាថាថ្នាក់អក្ខរកម្មមានដំណើរការប្រកបដោយប្រសិទ្ធិភាព



**រយៈពេល** : ប្រហែល៤៥នាទី



**សំភារៈចាំបាច់** : មេរៀនសំរាប់សិក្ខាកាមទី៥.២ ករណីសិក្សា

**វិធីសាស្រ្ត** : ការបំផុសគំនិត ពិភាក្សាជាគូ និងពិភាក្សាជាក្រុម



**របៀបសំរបសំរួលការបង្រៀន** :

១. សរសេរគោលបំណងមេរៀនលើក្រដាសផ្ទាំងធំ ឬលើក្តារខៀនរួចអាន និងពន្យល់សិក្ខាកាមពីគោលបំណងទាំងនោះ។

២. បែងចែកសិក្ខាកាមជា២ក្រុមធំ : ១ក្រុមតំណាងអោយអ្នកចូលរួម និងក្រុមមួយទៀតតំណាងអោយគ្រូបង្រៀនអក្ខរកម្ម។ ចែកមេរៀនសំរាប់សិក្ខាកាម និងសុំអោយពួកគាត់មើលសំនួរពិភាក្សាក្នុងរយៈពេល៥នាទីមុនពេលសំដែងរឿង។ តើបញ្ហាអ្វីដែលបានកំណត់នៅក្នុងករណីសិក្សា? តើអ្នកធ្លាប់ជួបប្រទះបញ្ហាបែបនេះនៅក្នុងឃុំរបស់អ្នកដែរឬទេ? សុំអោយអ្នកកត់ត្រាស្ម័គ្រចិត្តកត់ត្រានូវរាល់ចំណុចសំខាន់ៗនៃការពិភាក្សា។ ប្រសិនបើមានការងារច្រើនពេកអ្នកសំរបសំរួលអាចទទួលភារៈជាអ្នកកត់ត្រា។

៣. ជ្រើសរើសជនបង្គោលទទួលបន្ទុកកិច្ចការនារី និងកុមារម្នាក់ ដើម្បីធ្វើជាអធិបតីក្នុងអង្គប្រជុំ និងសុំអោយតំណាងក្រុមទាំងពីរអង្គុយទល់មុខគ្នានៅពេលប្រជុំ។ ជនបង្គោលទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ នឹងចាប់ផ្តើមបើកអង្គប្រជុំដោយនិយាយថា : វាដូចជាមានការលំបាកខ្លះៗជាមួយថ្នាក់អក្ខរកម្ម ការប្រជុំរបស់យើងនាថ្ងៃនេះធ្វើឡើង ដើម្បីពិនិត្យមើលបញ្ហាពិតប្រាកដ និងមធ្យោបាយដោះស្រាយបញ្ហាទាំងនេះ។

៤. ចែកមេរៀនសំរាប់សិក្ខាមកាម

# ផ្នែកទី៦: សមធម៌ផ្នែកយេនឌ័រ

**គោលបំណង** : នៅចុងបញ្ចប់នៃមេរៀនសិក្ខាកាមអាច :

- រៀបរាប់ពីសារៈសំខាន់ការសិក្សារបស់នារី
- កំណត់បាន ឧបសគ្គដែលបណ្ដាលអោយនារី មិនបានបញ្ចប់បឋមសិក្សា
- បង្កើតផែនការសកម្មភាព ដើម្បីជំនះលើ ឧបសគ្គទាំងនេះ



**រយៈពេល** : ប្រហែល៦០នាទី



**សំភារៈចាំបាច់** : ក្រដាសផ្ទាំងធំ និងហ្វឺត មេរៀនសំរាប់សិក្ខាកាមទី៤.២ មីណា-អ្នកដែលខ្លាចអ្នកសំឡុតគំរាម និងមីណា-រាប់សត្វមាន់ និងមេរៀនសំរាប់សិក្ខាកាមទី៤.៣

**វិធីសាស្ត្រ** : ការបំផុសគំនិត ពិភាក្សាជាក្រុម



**របៀបសំរបសំរួលការបង្រៀន** :

១. សរសេរគោលបំណងមេរៀនលើក្រដាសផ្ទាំងធំ ឬលើក្ដារខៀនរួចអាន និងពន្យល់សិក្ខាកាមពីគោលបំណងទាំងនោះ ។

<u>ផ្នែក ក</u>

២. បញ្ជាក់ប្រាប់សិក្ខាកាមថា យើងបាន និងកំពុងពិនិត្យទៅលើបញ្ហាការអប់រំដែលកុមារា និងកុមារីជួបប្រទះ។ យើងបានដឹងថា ទោះជាយ៉ាងណានៅតែមាន ឧបសគ្គទាំងផ្នែកសង្គម និងវប្បធម៌ កើតមានចំពោះកុមារី ដែលប៉ះពាល់ដល់លទ្ធភាពទទួលបានផលប្រយោជន៍ពីគោលនយោបាយការអប់រំសំរាប់ទាំងអស់គ្នារបស់ពួកគេ។

តាមរយៈការស្រាវជ្រាវយើងដឹងថា នៅក្នុងបណ្ដាប្រទេសភាគច្រើន ស្ត្រីជួបការលំបាកជាច្រើននៅពេលទៅសាលារៀន។ តើ ឧបសគ្គទាំងនេះមានអ្វីខ្លះ?

ចំលើយអាចមាន :

- មិនអាចទប់ទល់នឹងថ្លៃសាលា
- នៅក្នុងផ្ទះការអោយតំលៃរវាងកុមារា និងកុមារីមិនស្មើភាពគ្នា
- ប្រពៃណីដែលមិនអោយតំលៃទៅលើការសិក្សារបស់កុមារី
- រៀបការ និងមានផ្ទៃពោះនៅវ័យក្មេង

- ភ័យខ្លាចការរំលោភបំពានផ្លូវភេទ

៣. បែងចែកសិក្ខាកាមជាក្រុមដែលមានសមាជិក៥ឬ៦នាក់ និងពន្យល់ថាអ្នកនឹងផ្តល់ប្រធានបទអោយក្រុមនិមួយៗពិភាក្សា។ ពួកគាត់ត្រូវពិចារណាទៅលើសំនួរពីរ:

- តើអ្នកយល់ស្របនឹងប្រធានបទនេះដែរឬទេ?
- ប្រសិនបើអ្នកយល់ស្រប តើប្រធានបទនេះត្រឹមត្រូវតាមរបៀបណា? ប្រសិនបើមិនយល់ស្រប តើប្រធានបទនេះខុសទាស់ត្រង់ណា? ផ្តល់ឧទាហរណ៍ អោយបានច្រើនតាមលទ្ធភាព។

**"អប់រំនារីម្នាក់គឺអប់រំគ្រួសារទាំងមូល"**

**"ការស្រាវជ្រាវបង្ហាញអោយដឹងថា នៅពេល ដែលចំនួនស្ត្រីក្លាយជាអក្ខជនកើនឡើង ចំនួនមរណភាពកុមារអាយុក្រោម១ឆ្នាំធ្លាក់ចុះ យ៉ាងឆាប់រហ័ស"។**

ចំលើយអាចមាន: ជាពិសេសប្រសិនបើនាងក្រីក្រ ការរៀន សូត្របន្តជាប់រហូតគឺជាសញ្ញាដែលអនុញ្ញាតយ៉ាងមុតមាំថាកុមារ ដែលជាកូនៗរបស់នាងមានសុខភាពមាំមួន និងទទួលបានការអប់រំដ៏ប្រសើរ។ កុមារីដែលទទួលបានការអប់រំមានជំនាញ និងមានការជឿជាក់ ដើម្បីធ្វើខ្លួនជាម្តាយល្អ បុគ្គលិកល្អ និងជាប្រជាពលរដ្ឋល្អ។ អ្នកដែលបានទទួលការអប់រំជាអ្នកមានផលិតភាពខ្ពស់ទាំងនៅផ្ទះ និងនៅក្នុងការងារ និងបានទទួលកំរៃច្រើនពីការងាររបស់គេ។ នារីដែលទទួលបានការអប់រំល្អ យល់ច្បាស់ពីសារៈសំខាន់ការអប់រំ ហើយបញ្ជូនកូនៗរបស់គេទៅសាលារៀន។

**<u>ផ្នែក ខ</u>**

៤. សិក្ខាកាមស្ថិតតាមក្រុមដដែល គ្រូបង្គោលចែកករណីសិក្សាអោយសិក្ខាកាមធ្វើការពិភាក្សា និងប្រើប្រាស់តារាងម៉ាទ្រិច ដើម្បីកត់ត្រាបញ្ហា និងឫសគល់បញ្ហាទៅលើក្រដាសផ្ទាំងធំ។

៥. ក្រុមនិមួយៗត្រូវធ្វើការបង្ហាញជូនវគ្គសិក្សាទាំងមូល រំលឹកសិក្ខាកាមថា ពួកគាត់មិនត្រូវលើកបញ្ហាដដែលដូចដែលក្រុមដទៃបានធ្វើរួចមកហើយ។

**<u>ផ្នែក គ</u>**

៦. បញ្ជាក់ប្រាប់សិក្ខាកាមថា មានបញ្ហាចំបងពីរគឺ: តើមធ្យោបាយអ្វីខ្លះដែលអាចអោយកុមារីចុះឈ្មោះចូលរៀន និងទៅរៀនបន្តរហូត?

ត្រឡប់ទៅប្រើតារាងម៉ាទ្រិច ដោយមើលទៅលើឧបសគ្គ តើមានដំណោះស្រាយអ្វីខ្លះ និងតើអ្វីដែល គ.ក.ន.ក ត្រូវអនុវត្ត?

ចំលើយមាន:

- ថ្នាក់មត្តេយ្យ-ការចូលរៀនថ្នាក់ដំបូង
- ចាត់ចែងបង្កើតក្រុមការពារកុមារី
- បន្ទប់ស្នាក់នៅរួមសំរាប់កុមារី

- លប់បំបាត់ការបង់ថ្លៃសាលា
- អាហារូបករណ៍សំរាប់កុមារី
- លើកកំពស់ចំណេះដឹងសាធារណៈ អំពីសារៈសំខាន់របស់កុមារីចំពោះគ្រួសារ ក៏ដូចជាចំពោះសង្គម
- ជំរុញការជួលគ្រូបង្រៀនជានារី
- សាកល្បងអនុវត្តសាលារៀនចល័ត

៧. សង្កត់ធ្ងន់ថា ការផ្តល់សិទ្ធិអំណាចអោយនារី គឺជាមូលដ្ឋានសំរាប់ការផ្លាស់ប្តូរឥរិយាបទ និង អាកប្បកិរិយា ដែលរើសអើងចំពោះកុមារី និងនារី។ ការផ្តល់សិទ្ធិអំណាចអោយនារី ទាក់ទងទៅនឹងការផ្តល់សិទ្ធិអំណាចដល់កុមារី និងការទទួលបានយ៉ាងពេញលេញនូវសិទ្ធិរបស់ពួកគេ។

## ផ្នែកទី៧: បូកសរុបផែនការសកម្មភាព

**គោលបំណង** : នៅចុងបញ្ចប់នៃមេរៀនសិក្ខាកាមអាច :

- រំលឹកឡើងវិញពីបញ្ជីសកម្មភាពមួយចំនួន
- ចាត់អាទិភាពសកម្មភាពទាំងនោះ និងកំណត់រកដំណោះស្រាយ ដែលពួកគាត់ត្រូវការការតស៊ូមតិ ដើម្បីដាក់បញ្ចូលទៅក្នុងគំរោងវិនិយោគឃុំ
- បែងចែកការទទួលខុសត្រូវនៅក្នុង គ.ក.ន.ក
- ដាក់បញ្ចូលទៅក្នុងផែនការសកម្មភាពប្រចាំខែផ្ទាល់ខ្លួន
- ព្រមព្រៀងដាក់បញ្ចូលផ្នែកមួយ ស្តីពី ការពិនិត្យតាមដានសកម្មភាពទាំងនេះ នៅក្នុងរបៀបវារៈនៃការប្រជុំប្រចាំខែ



**រយៈពេល** : ប្រហែល៦០នាទី



**សំភារៈចាំបាច់** : ក្រដាសផ្ទាំងធំ និងហ្វឺត បិទតារាងម៉ាទ្រិចពីផ្នែកទី២-ទី៦ នៅលើជញ្ជាំង ក្រដាសផ្ទាំងធំមួយចំនួនត្រៀមសំរាប់ គ.ក.ន.ក (ក្រដាសមួយផ្ទាំងសំរាប់ គ.ក.ន.ក និមួយៗ)

**វិធីសាស្ត្រ** : ពិភាក្សាជាគូ ពិភាក្សាជាក្រុម



**របៀបសំរបសំរួលការបង្រៀន** :

១. សរសេរគោលបំណងមេរៀនលើក្រដាសផ្ទាំងធំ ឬលើក្តារខៀនរួចអាន និងពន្យល់សិក្ខាកាមពីគោលបំណងទាំងនោះ។

២. ពន្យល់សិក្ខាកាមថា នៅក្នុងរយៈពេលពីរថ្ងៃកន្លងទៅនេះយើងទាំងអស់គ្នាបានពិភាក្សាពីបញ្ហាជាច្រើន និងបានស្នើរនូវដំណោះស្រាយផ្សេងៗគ្នា ចំពោះបញ្ហា ដែលពាក់ព័ន្ធការអប់រំនៅក្នុងឃុំរបស់យើង។ ថ្ងៃនេះយើងនឹងរួមការងារជាមួយសមាជិក គ.ក.ន.ក របស់យើង ស្តីពី ការបូកសរុបផែនការសកម្មភាពសំរាប់ឃុំយើង។ ចែកសិក្ខាកាមជាក្រុមទៅតាមចំនួន គ.ក.ន.ក និងប្រគល់ក្រដាសផ្ទាំងធំ ដែលត្រៀមសំរាប់បង្កើតតារាងម៉ាទ្រិចអោយទៅក្រុមនិមួយៗ។

៣. សុំអោយ គ.ក.ន.ក ដើរមួយជ្រួលនៅក្នុងបន្ទប់ ពិនិត្យមើលតារាងម៉ាទ្រិច និងសំរេចពីតារាងម៉ាទ្រិចសំរាប់ឆ្នាំ២០០៥ នូវបណ្តាសកម្មភាពដែលត្រូវអនុវត្ត។ នៅក្នុងការពិភាក្សានេះសិក្ខាកាមត្រូវសំរេចពីអ្វី? អ្នកណា? នៅពេលណា? និងដូចម្តេច?

៤. ដោយប្រើប្រាស់តារាងម៉ាទ្រិចនៅមេរៀនទី១.២.៤ សិក្ខាកាមអាចរាយបញ្ជីសកម្មភាពដែលត្រូវអនុវត្តអ្នកទទួលខុសត្រូវ ដោយមានការគាំទ្រ/ក្នុងកិច្ចសហការជាមួយ និងពេលវេលា

កំណត់ត្រូវអនុវត្តន៍សកម្មភាព : “អ្នកត្រូវផ្តោតទៅលើជំហាន ជាក់លាក់ដែលត្រូវអនុវត្ត ក្នុងនាមជាសមាជិក គ.ក.ឧ.ក និងអ្នកតំណាងភូមិ”។

# ផ្នែកទី៨: វាយតំលៃវគ្គសិក្សា

**គោលបំណង** : សិក្ខាកាម និងគ្រូបង្គោលមានឱកាសវាយតំលៃរួមគ្នាពីវគ្គសិក្សា ។



**រយៈពេល** : ប្រហែល៣០នាទី



**សំភារៈចាំបាច់** : ហ្វីត ក្រដាសផ្ទាំងធំ និងប័ណ្ណសន្លឹកតូចៗ ឬក្រដាស post-its ពីរពណ៌ខុសគ្នា ( ឧទាហរណ៍ពណ៌ខៀវ និងពណ៌លឿង )អ្នកត្រូវការប័ណ្ណប្រហែល៤សំរាប់សិក្ខាកាមម្នាក់ (ពណ៌ខៀវ២សន្លឹក និងពណ៌លឿង២សន្លឹក)។ ត្រៀមក្រដាសផ្ទាំងធំគូសរង្វង់ដូចគ្នានឹងបន្ទះក្តារសំរាប់ គប់ ឬចោលព្រួញ ដើម្បីការវាយតំលៃបរិមាណ ។



**កំនត់សំគាល់សំរាប់គ្រូបង្គោល** : ការវាយតំលៃវគ្គសិក្សាជាឧបករណ៍យ៉ាងសំខាន់សំរាប់អោយអ្នកដឹងពីអ្វី ដែលត្រូវអនុវត្តបន្ត ឬពីអ្វី ដែលអ្នកអាចកែប្រែនៅពេលផ្តល់ការបណ្តុះបណ្តាលដូចគ្នានេះនៅពេលក្រោយ ។

**វិធីសាស្ត្រ** : ការផ្តល់មតិរបស់បុគ្គលម្នាក់ៗ ។



របៀបសំរបសំរួលការបង្រៀន :

១. សរសេរគោលបំណងមេរៀនលើក្រដាសផ្ទាំងធំ ឬលើក្តារខៀន រួចអាន និងពន្យល់សិក្ខាកាមពីគោលបំណងទាំងនោះ ។

២. សុំអោយសិក្ខាកាមគិតដោយខ្លួនឯងពីបទពិសោធន៍ ដែលគាត់បានជួបប្រទះក្នុងវគ្គសិក្សារយៈពេល២ថ្ងៃកន្លងមកនេះ ។

សុំអោយអោយគាត់ឆ្លើយនូវសំនួរដូចខាងក្រោម :

ក.តើអ្វី២យ៉ាងដែលអ្នកចូលចិត្តជាងគេបំផុត នៅក្នុងវគ្គសិក្សានេះ? (សរសេរលើប័ណ្ណពណ៌លឿង) **+**

ខ. តើអ្វី២យ៉ាង ដែលអ្នកមិនសូវពេញចិត្ត? (សរសេរលើប័ណ្ណពណ៌ខៀវ) **-**

៣. គូសតារាងពីរលើក្រដាសផ្ទាំងធំដើម្បីសរសេរសំនួរខាងលើ

៤. សុំអោយសិក្ខាកាមសរសេរនូវចំលើយនៅលើប័ណ្ណ រួចសុំអោយគេយកវាទៅបិទលើក្រដាសផ្ទាំងធំទៅតាមសំនួរដែលមានក្នុងតារាងនីមួយៗ។

៥. នៅលើក្រដាសផ្ទាំងធំគូសរង្វង់៤មានផ្ចិតរួមគ្នា ហើយបែងចែកជាបីផ្នែកដូចជា បន្ទះក្តាររាងជារង្វង់មួយ (សំរាប់គប់ ឬបាញ់ព្រួញ)។ ផ្នែកនីមួយៗមានសរសេរអំពីទិដ្ឋភាពវគ្គសិក្សាដែលយើងចង់ធ្វើការវាយតំលៃរួមមានៈ វិធីសាស្រ្ត ការសំរបសំរួល និងខ្លឹមសារ។ ដូចគ្នាទៅនឹងល្បែងគប់ ឬបាញ់ព្រួញដែរ គឺពិនិត្យនូវ បរិមាណគំនូសដែលមានក្នុងរង្វង់ :

- រង្វង់ខាងក្នុងបំផុតដាក់លេខ៤ (ល្អណាស់)
- រង្វង់ទី២ ខាងក្នុងបំផុត ដាក់លេខ៣ (ល្អ)
- រង្វង់ទី២ ខាងក្រៅបំផុត ដាក់លេខ២ (មធ្យម)
- រង្វង់ខាង ក្រៅបំផុត ដាក់លេខ១ (ខ្សោយ)




៦. ប្រាប់សិក្ខាកាមថាគាត់អាចដៅចំនុច៣ចំនុចសំរាប់ទិដ្ឋភាព៣ទិដ្ឋភាព (ចំណុចមួយសំរាប់ទិដ្ឋភាព១) ដោយគាត់ត្រូវគិតពីដំណើរការនៃទិដ្ឋភាពនីមួយៗដើម្បីធ្វើការអោយតំលៃ។

៧. នៅពេលដឹងថាសិក្ខាកាមបានយល់ច្បាស់ហើយ អ្នកត្រូវចេញពីបន្ទប់ ដើម្បីទុកអោយសិក្ខាកាម អាចបញ្ចេញគំនិតរបស់គាត់ដោយសេរី។

៨. សង្ខេបសកម្មភាពនោះដោយអោយសិក្ខាកាមមើលអ្វីដែលគាត់ចូលចិត្ត ឬមិនចូលចិត្ត។

៩. សង្ខេបលទ្ធផលនៃការវាយតំលៃដោយរូបមន្តខាងក្រោម :

ឧបមាថា សិក្ខាកាមសរុប២៦នាក់

- រាប់ចំនួនចំនុចនៅក្នុងរង្វង់នីមួយៗ ទៅតាមផ្នែកដែលបានចែក ហើយយកទៅគុណនឹងពិន្ទុរបស់រង្វង់ (ពិន្ទុរង្វង់ស្មើនឹងលេខរបស់រង្វង់)។

ឧទាហរណ៍ "ខ្លឹមសារ"

៥ចំនុច X ១ពិន្ទុ = ៥ពិន្ទុ

៦ចំនុច x ២ពិន្ទុ = ១២ពិន្ទុ

៧ចំនុច x ៣ពិន្ទុ = ២១ពិន្ទុ

៨ចំនុច x ៨ពិន្ទុ = ១៦ពិន្ទុ

-ពិន្ទុសរុបទាំង៨ជួរស្មើ ៥៤

-ចែកពិន្ទុសរុប និងចំនួនសិក្ខាកាមសរុបដើម្បីបានមធ្យមភាគ ៥៤:២២=២.៥។ នេះមានន័យថាអត្រាសរុបសំរាប់ខ្លឹមសារក្នុងវគ្គគឺ ២.៥

-ធ្វើដូចគ្នាចំពោះផ្នែកដែលនៅសល់

១០. អគុណសិក្ខាកាមចំពោះការចូលរួម និងការរិះគន់ត្រឡប់មកវិញរបស់គាត់

**មេរៀនទី ១.១**

# ស្វែងរកអ្នកណាម្នាក់ដែល...

| ស្វែងរកអ្នកណាម្នាក់ដែល.... | ឈ្មោះ |
|---|---|
| មានកូនច្រើនជាង៥នាក់ | |
| មានកូនអាយុពី៣-៥ឆ្នាំ | |
| មានកូនអាយុ៦ឆ្នាំ | |
| កំពុងរៀននៅក្នុងថ្នាក់អក្ខរកម្ម | |
| មានកូនបានបញ្ចប់ថ្នាក់បឋមសិក្សា | |

# គោលបំណងវគ្គសិក្សា



នៅចុងបញ្ចប់នៃមេរៀននេះសិក្ខាកាមនឹង :

១. អាចកំណត់សារៈសំខាន់ និងបញ្ហាអប់រំបន្ទាន់នៅក្នុងឃុំ និងមូលហេតុបញ្ហាទាំងនោះ

២. អាចកំណត់សេវាកម្ម ដែលអាចរកបានក្នុងឃុំ ដើម្បីដោះស្រាយបញ្ហាទាំងនេះ និងបំពេញនូវកង្វះខាត

៣. អាចបង្កើតផែនការសកម្មភាពស្តីពីអ្វី ដែលត្រូវអនុវត្ត ដើម្បីដោះស្រាយបញ្ហាទាំងនេះ ដោយមានកិច្ចសហការណ៍ពីអ្នកមានតួនាទីពាក់ព័ន្ធដទៃ

**មេរៀនទី ១.២.១**

# ករណីសិក្សា-រឿងរបស់សុផារី

សុផារីគឺជាជនបង្គោលទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ នៅក្នុងឃុំល្អ ស្រុកមែនទែន ខេត្តលេខមួយ។ គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារទើបតែត្រូវបង្កើតឡើងនៅក្នុងឃុំល្អ ហើយក្នុងពេលនេះមានសមាជិក៥រូបកំពុងធ្វើការរួមគ្នា ដើម្បីកែលំអស្ថានភាពនារី និងកុមារអោយបានប្រសើរឡើង។

សុផារីទើបបានចុះកិច្ចព្រមព្រៀងផ្តត់ផ្គង់សេវាកម្ម និងជួបជាមួយអ្នកគ្រប់គ្រងការងាររបស់នាងដែលមកពីថ្នាក់ស្រុក ស្តីពីកិច្ចការប្រចាំឆ្នាំរបស់នាង។ សុផារីរំភើបចំពោះភារកិច្ចថ្មីរបស់នាង ប៉ុន្តែវាទាក់ទងទៅនឹងអ្វីដែលនាងមិនសូវមានចំណេះដឹង។ ប្រសិនបើនាងត្រូវស្វែងរកការគាំទ្រមតិចំពោះបញ្ហា អាហាររូបត្ថម្ភ ទឹកស្អាត និងអនាម័យ សារៈសំខាន់ការអប់រំកុមារវ័យដំបូង ឬពលកម្មកុមារ តើនាងយល់ដឹងគ្រប់គ្រាន់នឹងប្រាប់ទៅប្រជាជនក្នុងភូមិដែរឬទេ? តើពួកគេនឹងស្តាប់នាងឬទេ?

**មេរៀនទី ១.២.២**

# ការចោទសួរពីបញ្ហាដែលកើតមានឡើង

នៅក្នុងបញ្ហាកើតមានឡើងនេះ យើងត្រូវចោទសំនួរបើកចំនួន៤ :

| ល.រ | សំនួរបើក | លទ្ធផលរំពឹងទុក |
|---|---|---|
| ១ | តើមានអ្វីកើតនៅទីនេះ ឬក្នុងដំណើររឿងនេះ? | ការពិពណ៌នា |
| ២ | តើអ្នកគិតថាវាកើតឡើងដោយសារមូលហេតុអ្វី? | ការវិភាគ |
| ៣ | នៅពេលដែលវាកើតឡើង តើវាបណ្តាលអោយមានបញ្ហាអ្វីខ្លះ? | វិបាក ឬផលប៉ះពាល់ |
| ៤ | តើយើងអាចធ្វើអ្វីខ្លះ ចំពោះបញ្ហានេះ? | ការសំរេចសកម្មភាព-ដំណោះស្រាយ |

ការចោទសួរពីបញ្ហាដែលកើតមានឡើងគឺជា ការសិក្សាពីបញ្ហាដែលកើតមានឡើង តាមរយៈការផ្តល់អោយ នូវករណីសិក្សា ការស្តាប់ ឬមើលរូបភាព វីដេអូ ហើយសិក្ខាកាមត្រូវចោទសួរដោយសំនួរបើកចំនួន៤។ វិធីសាស្ត្រនេះនឹងជំរុញអោយមានការវិភាគ និងរកដំណោះស្រាយបញ្ហា ដោយការធ្វើអោយអ្នកចូលរួម គិត និងរៀនសូត្រ។ វាក៏ត្រូវបានជឿជាក់ផងដែរថាសិក្ខាកាមមានចំណេះដឹងប្រសើរបំផុតពីស្ថានភាពក្នុងមូលដ្ឋាន និងគឺពួកគាត់ទាំងនេះហើយដែលជាអ្នកបង្កើតនូវដំណោះស្រាយបានយ៉ាងល្អបំផុត។ ម្យ៉ាងវិញទៀតវត្ថុសិក្សានេះ នឹងធ្វើអោយសិក្ខាកាមទៅជាអ្នកដែលទាក់ទងក្នុងដំណើរការបណ្តុះបណ្តាល គឺជាអ្នកដែលធ្វើសេចក្តីសំរេចរាល់បញ្ហាផ្ទាល់ខ្លួនរបស់គាត់។

**មេរៀនទី ១.២.៣**

## រចនាសម្ព័ន្ធវគ្គសិក្សា

មេរៀនក្នុងវគ្គកសាងសមត្ថភាពនេះមានរចនាសម្ព័ន្ធដូចតទៅ:

១. ប្រើប្រាស់ករណីសិក្សា ពត៌មាន ស្តីពី ស្ថានភាពឃុំ និងពត៌មានផ្សព្វផ្សាយពីបញ្ហាប្រឈមរបស់នារី និងកុមារនៅក្នុងផ្នែកសុខភាព ការអប់រំ និងកិច្ចការពារកុមារ។ វិភាគរកមូលហេតុបញ្ហា និងពិភាក្សា ពីផលប៉ះពាល់ និង លទ្ធផលដែលពាក់ព័ន្ធសំរាប់នារី និងកុមារ និងសង្គមជាតិទាំងមូល។

២. តើសេវាប្រពន្ធ័ជាបង្អែកអ្វីខ្លះ ដែលផ្តល់អោយដោយក្រសួងជំនាញ និងអង្គការក្រៅរដ្ឋាភិបាលដទៃ ឬសង្គមស៊ីវិល ដើម្បីដោះស្រាយបញ្ហាទាំងនេះ?

៣. តើក្រុមប្រឹក្សាឃុំ ជាពិសេស គ.ក.ន.ក ជាមួយនិងតំណាងភូមិអាចធ្វើអ្វីខ្លះ ដើម្បីបង្កើនការផ្តត់ផ្គង់សេវាទាំងនេះអោយបានជាអតិបរមា? តើអ្នកផ្គត់ផ្គង់សេវាកម្មត្រូវមានតួនាទីអ្វីខ្លះ ដើម្បីធានានូវតំលៃ និងភាពសមស្របរបស់សេវាកម្មដែលបានផ្តល់?

នៅក្នុងផ្នែកនេះ ជាសំខាន់ គឺធ្វើអោយសិក្ខាកាមផ្តោតទៅលើ “តើអ្វី ដែលខ្ញុំអាចធ្វើបាននៅក្នុងស្ថានការណ៍នេះ”។ យើងដឹងហើយថាមានរឿងរ៉ាវជាច្រើនដែលអ្នកមានតួនាទីខុសៗគ្នានៅក្នុងការអភិវឌ្ឍន៍ប្រទេសកម្ពុជាត្រូវអនុវត្ត។ ទោះជាយ៉ាងណាយើងមិនអាចកំណត់ថា ត្រូវធ្វើនៅពេលណា ប៉ុន្តែបើក្នុងមធ្យោបាយតូចមួយរបស់យើង យើងអាចធ្វើអ្វីៗដែលធ្វើអោយមានការផ្លាស់ប្តូរនោះ យើងត្រូវតែធ្វើ។

*“ការផ្តល់សិទ្ធិអំណាចដែលល្អបំផុតគឺការផ្តល់សិទ្ធិអំណាចអោយខ្លួនឯង”*

**មេរៀនទី ១.២.៤**

# ការវិភាគស្ថានភាព និងផែនការសកម្មភាព

វគ្គសិក្សានេះមានគោលបំណងវិភាគស្ថានភាពពាក់ព័ន្ធដល់នារី និងកុមារ ជាមួយគ្នានេះបានជាជំនួយដើម្បីបង្កើតនូវផែនការសកម្មភាពសំរាប់ គ.ក.ន.ក ដោយប្រើប្រាស់គំរូតារាងម៉ាទ្រិចដូចខាងក្រោម:

តារាងម៉ាទ្រិចវិភាគស្ថានភាព និងផែនការសកម្មភាព

| ល.រ | ស្ថានភាព | ឫសគល់បញ្ហា | ដំណោះស្រាយ | *សកម្មភាពត្រូវអនុវត្ត* | *អ្នកទទួលខុសត្រូវ* | *ដោយមានការគាំទ្រពីក្នុងកិច្ចសហការណ៍ជាមួយ* | *ពេលវេលាកំណត់* |
|---|---|---|---|---|---|---|---|
| | | | | | | | |
| | | | | | | | |
| | | | | | | | |

ប៉ុន្តែដោយសារចំនួនប្រឡោះបញ្ឈរមានច្រើនពេក ធ្វើអោយតារាងម៉ាទ្រិចនេះមិនអាចយកទៅប្រើប្រាស់នៅលើក្រដាសផ្ទាំងធំ ឬនៅលើក្តារខៀនបានងាយស្រួល។ យើងនឹងប្រើប្រាស់តារាងម៉ាទ្រិច ដែលបែងចែកជាពីរផ្នែក (ពណ៌ខៀវ និង ពណ៌បៃតង)

**ផ្នែក ក:** ការវិភាគស្ថានភាព

| ល.រ | ស្ថានភាព | ឫសគល់បញ្ហា | ដំណោះស្រាយ |
|---|---|---|---|
| | | | |
| | | | |
| | | | |

**ផ្នែក ខ:** ផែនការសកម្មភាព

| *ល.រ* | *សកម្មភាពត្រូវអនុវត្ត* | *អ្នកទទួលខុសត្រូវ* | *ដោយមានការគាំទ្រពីក្នុងកិច្ចសហការណ៍ជាមួយ* | *ពេលវេលាកំណត់* |
|---|---|---|---|---|
| | | | | |
| | | | | |
| | | | | |



**មេរៀនទី ១.២.៥**

# តើអ្នកអាចធ្វើអ្វីខ្លះ?

តើក្រុមប្រឹក្សាឃុំ និងតំណាងភូមិអាចធ្វើអ្វីខ្លះ ដើម្បីកែលំអស្ថានភាពនារី និងកុមារក្នុងសហគមន៍អោយបានប្រសើរ?

**ទំលុះភាពស្ងៀមស្ងាត់**

- ជួយប្រមូលពត៌មានពិត និងតួលេខពីបញ្ហាទាំងឡាយដែលកើតមាននៅក្នុងសហគមន៍របស់អ្នក
- ប្រើប្រាស់ពត៌មានទាំងនេះដើម្បីបញ្ចុះបញ្ចូលក្រុមគ្រួសារ មិត្តភក្តិ និងសហគមន៍របស់អ្នកពីសារៈសំខាន់បញ្ហាសុខភាព ការអប់រំ និងកិច្ចការពារកុមារ ដើម្បីលើកកំពស់ស្ថានភាពនារី និងកុមារក្នុងសហគមន៍ទាំងមូល

**អប់រំ ផ្តល់ដំណឹង និងបញ្ជាប់កម្ពស់ចំណេះដឹង និងការរើសអើង**

- ទុកឱកាសអោយស្ថាប័នមូលដ្ឋាន និងសហគមន៍យល់ដឹងពីបញ្ហាពាក់ព័ន្ធ និងពីអ្វី ដែលពួកគេអាចធ្វើដោយខ្លួនឯង ដើម្បីកែលំអស្ថានភាពអោយបានប្រសើរ។ នៅពេលដែលពួកគេត្រូវការនូវជំនួយ តើអ្នកណា និងទីខ្លែងណាដែលអាចផ្តល់ការគាំទ្រ និងការថែទាំដល់ពួកគេ។

**ការពារមិនអោយមានការរើសអើង**

- អំពាវនាវរកជំនួយសប្បុរសធម៌ ការគាំទ្រ និងកិច្ចការពារសំរាប់នារី និងកុមារងាយទទួលគ្រោះថ្នាក់ នៅក្នុងរង្វង់គ្រួសារ និងសហគមន៍។ អ្នកត្រូវធ្វើជាគំរូអោយគេគ្រប់គ្នា
- បង្កើតសម្ព័ន្ធភាពរវាងសហគមន៍ និងយុវជនក្នុងសហគមន៍ដែលអាចបញ្ចប់ការរើសអើងចំពោះពួកគេ

ចលនាសកម្មភាព

- ចលនាសហគមន៍អោយផ្តួចផ្តើមដោះស្រាយបញ្ហាដោយខ្លួនឯង
- ប្រើប្រាស់ដំណើរការកសាងផែនការមូលដ្ឋាន ដើម្បីស្វែងរកការគាំទ្រមតិចំពោះការវិភាជន៍ថវិកាសំរាប់ សុខុមាលភាព សេវាសង្គម និងសេវាផ្តល់ការគាំទ្រដល់នារី និងកុមារ
- លើកកំពស់ និងពង្រឹងការថែទាំដែលមានមូលដ្ឋានតាមគ្រួសារ និងសហគមន៍តាមរយៈមន្ទីរជំនាញពាក់ព័ន្ធ
- ធានាថាកុមារទាំងអស់បានទទួលសេវាសង្គមគ្រប់គ្រាន់ ដោយរួមបញ្ចូលទាំង សុខភាព អាហារូបត្ថម្ភ តាមរយៈការស្វែងរកការគាំទ្រមតិជាមួយនឹងមន្ទីរជំនាញពាក់ព័ន្ធ
- ស្វែងរកការគាំទ្រមតិសំរាប់យន្តការណ៍ដែលផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុដល់ឪពុកម្តាយ គ្រួសារ និងគ្រួសារជួបបញ្ហា ដូចជាតាមរយៈការកាត់បន្ថយ ឬលុបបំបាត់ការបង់ថ្លៃសាលារៀន និងការផ្តល់ជំនួយសំរាប់ការថែទាំកុមារកំព្រាដែលមានមូលដ្ឋាននៅសហគមន៍

- វិធីកែលំអការទទួលបាននូវសេវាដែលផ្តល់ដោយមន្ទីរជំនាញ របស់ជនងាយទទួលគ្រោះថ្នាក់នៅក្នុងសហគមន៍

**ផ្តល់អាទិភាពខ្ពស់ដល់ជនក្រីក្របំផុតនៅក្នុងសហគមន៍**

- ជំរុញការកម្មវិធីជួយជនក្រីក្រ និងប្រើប្រាស់ឧបករណ៍កំណត់រកជនក្រីក្របំផុតនៅក្នុងសហគមន៍ និងផ្តល់នូវជំនួយដែលគេត្រូវការសំរាប់ជីវភាពរស់នៅរបស់គេ។

**លើកទឹកចិត្ត និង ជំរុញការចូលរួមរបស់កុមារ**

- ទោះជានៅទីកន្លែងណា ការយកចិត្តទុកដាក់ពីសមត្ថភាពរបស់កុមារគឺ ធានាថាកុមារជំទង់បានចូលរួមក្នុងការកសាងផែនការ និងដំណើរការសេវាកម្មដែលមានផលប៉ះពាល់ទៅលើពួកគេ
- តាមរយៈសមាគមន៍យុវជន ឬយុវជនកាយារិទ្ធិថ្លូវការ ធ្វើការពិភាក្សាបញ្ហា ដែលចោទឡើងចំពោះពួកគេ

**ចាត់ចែងសេវាដែលមានមូលដ្ឋាននៅសហគមន៍**

- ដោយប្រើប្រាស់មូលនិធិឃុំ រៀបចំចាត់ចែងសេវាដែលមានមូលដ្ឋាននៅសហគមន៍ ដូចជា មត្តេយ្យសហគមន៍ ឬថ្នាក់អក្ខរកម្មសហគមន៍។
- ពិនិត្យ តាមដាន សេវាដែលផ្តល់អោយដោយមណ្ឌលសុខភាព សាលារៀន និងមន្ទីរ ដែលផ្តល់សេវាកម្មសង្គមកិច្ច
- គាំទ្រផែនការសេវា ដែលផ្តល់អោយដោយមណ្ឌលសុខភាព សាលារៀន និងមន្ទីរដែលផ្តល់ សេវាកម្មសង្គមកិច្ច

# ការអប់រំជាយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ

ភ្ជាប់ប្រឡោះបញ្ឈរ ក ខ និង គ

| ក | ខ | គ |
|---|---|---|
| ១,៥លាន | ប្រជាជនកម្ពុជា | ចេះអាន និងសរសេរ។ |
| ៥,៧នាក់ក្នុងចំណោម១០នាក់ | បុរសកម្ពុជា | ចេះអាន និងសរសេរ។ |
| ៨នាក់ក្នុងចំណោម១០នាក់ | ស្ត្រីកម្ពុជា | ជាអនក្ខរជន។ |

រដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជាបានចែងថា
“រដ្ឋផ្តល់កិច្ចការអប់រំថ្នាក់បឋមសិក្សា និងមធ្យមសិក្សានៅសាលារៀនសាធារណៈ
សំរាប់ប្រជាពលរដ្ឋគ្រប់រូប ដោយឥតមានបង់ថ្លៃ” (មាត្រាទី៦៨)

ពង្រាងច្បាប់អប់រំក៏មានចែងថា
“ប្រជាជនកម្ពុជាមានសិទ្ធិទទួលបានការអប់រំដោយមិនបង់ថ្លៃ
រយៈពេល៩ឆ្នាំ នៅតាមសាលារដ្ឋ”

**មេរៀនទី ៣.១**

# តើអ្វីខ្លះដែលអាចជួយអោយកុមារអាយុពី០-៣ឆ្នាំធ្វើការអភិវឌ្ឍន៍បានល្អ?

ចំពោះកុមារតូច ភាគច្រើនបំផុតនៃការអភិវឌ្ឍន៍ខួរក្បាលរបស់គេកើតឡើងនៅមុនពេលគេមានអាយុគ្រប់២ឆ្នាំ។ ដូច្នេះ វាមានសារៈសំខាន់ណាស់ក្នុងការធ្វើអោយកុមារមានសុខភាព អាហារូបត្ថម្ភ និងស្ថានភាពចិត្ត-សង្គមរបស់កុមារបានប្រសើរឡើង

- ការពារកុមារពីគ្រោះថ្នាក់ដល់រាងកាយ
- មានអាហារូបត្ថម្ភ និងការថែទាំសុខភាពគ្រប់គ្រាន់
- ទទួលបានថ្នាំបង្ការគ្រប់គ្រាន់
- មានភាពជិតស្និទ្ធជាមួយមនុស្សចាស់
- មានមនុស្សចាស់ដែលអាចយល់ និងឆ្លើយតបទៅកុមារវិញ
- មានវត្ថុ អោយគេមើល ប៉ះ ស្តាប់ឮ ស្រង់ក្លិន និងភ្លក់រសជាតិ
- មានឱកាសរកឃើញ និងស្រាវជ្រាវរកពាក្យគេចង់ប្រើ
- យកចិត្តទុកដាក់ចំពោះការប្រើប្រាស់ភាសាកំណើត
- យកចិត្តទុកដាក់ និងគាំទ្រ ក្នុងការទទួលនូវសមត្ថភាពថ្មី ការអភិវឌ្ឍន៍ជំនាញភាសា និងការគិត
- រៀនពីរបៀបគ្រប់គ្រងលើឥរិយាបថរបស់ពួកគេ
- ឱកាសលេងរបស់កុមារ







**មេរៀនទី ៣.២**

# ហេតុអ្វីត្រូវបញ្ជូនកូនៗរបស់អ្នកទៅរៀននៅថ្នាក់មត្តេយ្យសហគមន៍?

តាមការស្រាវជ្រាវបានអោយដឹងថា ការបញ្ជូនកុមារអោយទៅរៀននៅថ្នាក់មត្តេយ្យមានសារៈប្រយោជន៍ជាច្រើន:

១. លើកកំពស់ការចូលរៀនថ្នាក់ដំបូង និង បឋមសិក្សា
២. ជំរុញ និងបង្កើនការចូលរៀនថ្នាក់ទី១នៅពេលកុមារមានអាយុ៦ឆ្នាំ
៣. កាត់បន្ថយការរៀនត្រួតថ្នាក់ និងអត្រាបោះបង់ចោលការសិក្សា
៤. ធ្វើអោយសិទ្ធិកុមារសំរេចបានយ៉ាងពេញលេញ ដើម្បីអោយពួកគេទទួលបានសេវា ដែលអាចដោះស្រាយតំរូវការរបស់ពួកគេ
៥. បង្កើនឱកាស និងសកម្មភាពស្មើភាពគ្នានៃកុមារពិការ

**មេរៀនទី ៤.១**

# ការអប់រំជាមូលដ្ឋាន ក្នុងប្រព័ន្ធ

## ករណីសិក្សាទី១ : ការអប់រំក្នុងប្រព័ន្ធ

សាលាបឋមសិក្សាត្រឡែងកែងស្ថិតនៅក្នុងឃុំខ្ពស់ ជាសាលាដែលមានអត្រាបោះបង់ចោលសាលារៀនដល់ទៅ៧% និងជាអត្រាខ្ពស់ជាងគេបំផុតនៅក្នុងខេត្ត។ ភូមិជាច្រើនក្នុងឃុំនេះស្ថិតនៅក្នុងតំបន់ដាច់ស្រយាលឆ្ងាយពីទីប្រជុំជន និងមានចំងាយយ៉ាងតិច២,៥គ.មពីសាលារៀន។ នៅព្រឹកព្រលឹមមួយពេលដែលពូចែវកំពុងជិះកង់ទៅធ្វើការ គាត់បានឃើញក្មេងៗមួយក្រុម ក្នុងនោះមានក្មេងស្រី២នាក់ក្មេងប្រុស៣នាក់កំពុងជិះលើខ្នងក្របីច្រៀងលេងយ៉ាងសប្បាយ។ គាត់ឈប់កង់ ហើយសួរទៅក្មេងៗទាំងនោះថា"នែ៎! ក្មួយៗទាំងឡាយតើថ្ងៃនេះជាថ្ងៃអ្វី?"ក្មេងៗទាំងនោះឆ្លើយយ៉ាងរហ័សថា"ថ្ងៃអង្គារ លោកពូ" ពូចែវសួរតទៅទៀតថា"ចុះពួកក្មួយអត់ទៅរៀនទេឬ?"។ ក្មេងប្រុសម្នាក់ឆ្លើយឡើងថា "បាទយើងត្រូវទៅរៀន តែពុក និងម៉ែពួកខ្ញុំអោយឈប់រៀន៣ថ្ងៃ ដើម្បីជួយឃ្វៀលក្របីគាត់ត្រូវច្រូតស្រូវបង្កើយ"។ ពូចែវបន្តទៀតថា"អីចឹងទេ! តើពួកក្មួយគិតឃើញយ៉ាងណាដែរនៅពេលត្រឡប់ទៅរៀនវិញបន្ទាប់ពីឈប់៣ថ្ងៃនេះ?"។

ពួដូច្នេះក្មេងៗទាំងនោះចាប់ផ្តើមរៀបរាប់ប្រាប់ពូចែវពីបញ្ហាដែលពួកគេជួបប្រទះនៅពេល ដែលគេមិនបានទៅរៀនអោយបានជាប់លាប់។ **វុធ** និងមិត្តជិតខាងរបស់គេឈ្មោះ**ថាប**ត្រូវរៀនត្រួតថ្នាក់ នៅថ្នាក់ទី៣ ឯមិត្តរបស់គេម្នាក់ទៀតឈ្មោះ**វិទ្ធ**ចាប់ផ្តើមពិបាកយល់ និងតាមអោយទាន់មេរៀននៅក្នុងថ្នាក់ ហើយក៏មិនចង់ទៅសាលារៀនទៀតដែរ។

ពូចែវបែរទៅរកក្មេងស្រីទាំងពីរ និងសួរថា"ចំណែកក្មួយៗវិញ ក្មេងស្រីតូច? តើក្មួយគិតយ៉ាងណា?" **នាង**ក្មេងស្រីដែលមានអាយុប្រហែល១៣ឆ្នាំឆ្លើយថា "ខ្ញុំមិនមែនក្មេងតូចទៀតទេលោកពូ! ខ្ញុំស្រលាញ់សាលារៀនណាស់ ហើយខ្ញុំខំរៀនអាននៅផ្ទះដូច្នេះខ្ញុំមិនជួបការលំបាកនឹងយល់មេរៀនទេ ប៉ុន្តែពុក និងម៉ែរបស់ខ្ញុំ គាត់ចង់អោយខ្ញុំរៀបការនៅឆ្នាំក្រោយ ដូច្នេះខ្ញុំមិនអាចបញ្ចប់ថ្នាក់ទី៦បានឡើយ។" ក្មេងស្រីម្នាក់ទៀតឈ្មោះសុភាពបានពន្យល់ថា ឪពុករបស់ខ្លួនមានជំងឺធ្ងន់ធ្ងរ ហើយនាងប្រហែលជាឈប់រៀនដូចក្មេងស្រីឈ្មោះ**នាង**ដែរ ដើម្បីស្វែងរកការងារធ្វើរកប្រាក់ជួយគ្រួសារ។

នៅក្នុងក្រុមរបស់អ្នក សូមធ្វើការវិភាគស្ថានភាពដោយប្រើប្រាស់តារាងម៉ាទ្រិចខាងក្រោម។ ចូរចងចាំថាដំណោះស្រាយត្រូវស្ថិតក្រោមឥទ្ធិពល និងអណត្តិរបស់ គ.ក.ន.ក និអ្នកតំណាងភូមិ។

| ល.រ | បញ្ហា | ឬសគល់បញ្ហា | ដំណោះស្រាយ |
|---|---|---|---|
| | | | |
| | | | |
| | | | |

**មេរៀនទី ៥.១**

# ថ្នាក់អក្ខរកម្ម

ចែកសិក្ខាកាមជា២ក្រុមធំ

ក្រុម ក : គិតថាអ្នកគឺជាធីតា និងក្មេងប្រុស ស្រី ដទៃទៀតដែលដូចធីតា។ តើអ្វីជាមូលហេតុដែលធ្វើអោយពួកគេមិនបានទៅសាលារៀន?

ក្រុម ខ : អ្នកជាសមាជិក គ.ក.ន.ក នៅក្នុងឃុំល្អី តើអ្នកត្រូវធ្វើអ្វីដើម្បីជួយកែលំអស្ថានភាពនេះអោយបានប្រសើរឡើង?

## ករណីសិក្សាទី៣ : ថ្នាក់អក្ខរកម្ម

**ផ្នែកទី១**

ថ្ងៃមួយប៊ុនធីបានធ្វើដំណើរជាមួយអ្នកទេសចរមួយក្រុម មានគ្នា៤នាក់មកពីប្រទេសកាណាដា ទៅកាន់ទឹកធ្លាក់អូរអញ្ចាញនៅភ្នំយា ឃុំល្អី ស្រុកកញ្ជៀរ។ បន្ទាប់ពីពួកគេសំរាកអង្គុញផឹកទឹកដូងបានបន្តិច មានក្មេងស្រីជំទង់ម្នាក់ឈ្មោះធីតា ចូលមកជិតពួកគេដោយនាំយកវត្ថុអនុស្សាវរីយ៍សំរាប់លក់មកជាមួយផង។ វត្ថុអនុស្សាវរីយ៍ទាំងនោះមានខ្សែដៃ ចិញ្ចៀន និងបន្តោងសំរាប់ដាក់កូនសោធ្វើអំពីត្រឡោកដូង។ អ្នកទេសចរណ៍ម្នាក់ឈ្មោះចនចង់បានបន្តោងសំរាប់ដាក់កូនសោ ហើយខ្ញុំជំនួសអោយចនបានសួរទៅក្មេងស្រីនោះថា "តើបន្តោងសំរាប់ដាក់កូនសោមួយថ្លៃប៉ុន្មាន?"នាងឆ្លើយថា"១ថ្លៃ១៥០០រ"។ ចនទិញបន្តោងសំរាប់ដាក់កូនសោនោះ៥ ដូច្នោះខ្ញុំក៏សួរនាងថា "តើបន្តោងទាំង៥ហ្នឹងថ្លៃប៉ុន្មាន?"។

ក្មេងស្រីនោះគិតអស់មួយសន្ទុះ ប៉ុន្តែនាងមិនអាចគិតឃើញពីតំលៃសរុបសំរាប់បន្តោងដាក់កូនសោទាំង៥ឡើយ។ "តើប្អូនធ្លាប់បានទៅរៀនដែរទេពីមុនមក?"ខ្ញុំជជីកសួរ។ ក្មេងស្រីឆ្លើយថា"ខ្ញុំធ្លាប់ទៅរៀនកាលខ្ញុំនៅក្មេង តែឥឡូវនេះខ្ញុំធំពេកហើយ និងមិនដឹងថាត្រូវទៅរៀននៅឯណាទេ?"

**សំនួរពិភាក្សា :**

១. តើអ្នកគិតថាទីកន្លែងណាដែលធីតាត្រូវទៅប្រសិនបើនាងចង់រៀនអាន និងរៀនសរសេរ?

២. ប្រសិនបើគ្មានថ្នាក់អក្ខរកម្មនៅក្នុងភូមិ ឬឃុំ តើក្រុមប្រឹក្សាឃុំត្រូវធ្វើអ្វី?





**មេរៀនទី ៥.២**

# ថ្នាក់អក្ខរកម្ម

ចែកសិក្ខាកាមជា២ ក្រុមធំ

ក្រុម ក : តំណាងធីតា និង ក្រុមនារីជំទង់

ក្រុម ខ : តំណាង គ្រូអក្ខរកម្ម

ក្រុមនិមួយ ត្រូវជ្រើសរើស:

- អ្នកដឹកនាំការពិភាក្សាម្នាក់
- អ្នកកត់ ត្រាម្នាក់
- អ្នកតំណាងពីរនាក់សំរាប់ការសន្ទនា

## ផ្នែកទី២

នៅក្នុងឃុំល្អីមានក្មេង ស្រីជំទង់ ដែលជាអនក្ខរជនដូច**ធីតា**ជា ច្រើននាក់ ហេតុនេះទើបបានជានៅក្នុងដំណើរការកសាងផែនការឃុំ នាឆ្នាំកន្លងទៅ ក្រុម ប្រឹក្សាឃុំបានលើកបញ្ហានេះជាអាទិភាពខ្ពស់នៅក្នុងផែនការកម្មវិធីអភិវឌ្ឍន៍ឃុំ និងបានចុះកិច្ច ព្រមព្រៀងបណ្តោះអាសន្នជាមួយមន្ទីរអប់រំខេត្ត ដើម្បីចាប់ដំណើរការថ្នាក់អក្ខរកម្មចំនួន ២ មួយនៅក្នុងភូមិតា និងមួយទៀតនៅក្នុងភូមិយាគីជាភូមិ ដែល ត្រូវបានកំណត់រកឃើញថា មានអ ត្រាអនក្ខរជនច្រើនជាងភូមិដទៃក្នុងឃុំ ។

**ប៊ុនធី** និង**ធីតា** បានទៅថ្នាក់អក្ខរកម្មដែលស្ថិតក្នុងភូមិតា ផ្អែកតាមពតិមានដែលបានផ្តល់អោយដោយស្មៀនឃុំ។ គ្រូបង្រៀនអក្ខរកម្មគឺអ្នក ស្រីសុ**ជាតិ**កំពុងធ្វើការនៅទីនោះ ប៉ុន្តែគ្មានឃើញសិស្សណាម្នាក់ឡើយ ទោះបីជាមានមនុស្សដល់ទៅ១៥នាក់បានចុះឈ្មោះចូលរៀនក៏ដោយ ។ អ្នក គ្រូសុ**ជាតិ**បានទទួល ប្រាក់ ឧបត្ថម្ភពីមន្ទីរអប់រំខេត្ត និងធ្លាប់ទទួលការបណ្តុះបណ្តាលយ៉ាងល្អពីអង្គការ ក្រៅរដ្ឋាភិបាលមួយ ស្តីពី ជំនាញក្នុងការបង្រៀននៅថ្នាក់អក្ខរកម្ម ហើយនាងក៏មានសំភារ :ចាំបាច់ គ្រប់ គ្រាន់សំរាប់ការបណ្តុះបណ្តាលផងដែរ ។



**មេរៀនទី ៦.១**

# ការអប់រំសំរាប់កុមារី

"អប់រំកុមារីម្នាក់គឺអប់រំ គ្រួសារទាំងមូល!"





| | | |
|---|---|---|
| ៨នាក់ក្នុងចំណោម១០នាក់ | ស្ត្រីកម្ពុជា | ជាអនក្ខរជន |

| | | |
|---|---|---|
| ១,៥លាន | ប្រជាជនកម្ពុជា | ចេះអាន និងសរសេរ |

| | |
|---|---|
| ៥,៧នាក់ក្នុងចំណោម១០នាក់ | បុរសកម្ពុជា |

| |
|---|
| ចេះអាន និងសរសេរ |

មេរៀន

(សំរាប់សិក្ខាកាម)

# វគ្គកសាងសមត្ថភាព សំរាប់ក្រុមប្រឹក្សាឃុំ
# ស្តីពី
# បញ្ហាការអប់រំ ដែលប៉ះពាល់ដល់នារី និងកុមារ